ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# របាយការណ៍
## ស្តីពីលទ្ធផលការវាយតម្លៃផលប៉ះពាល់លើប្រកាសរួម ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស



រៀបចំដោយក្រុមការងារអនុវត្តគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
សហការជាមួយក្រុមការងារប្រតិបត្តិគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃទីស្តីការគណៈរដ្ឋមន្ត្រី

ខែមករា ឆ្នាំ២០១៥

# គម្រោងរបាយការណ៍
# ស្តីពីលទ្ធផលនៃការវាយតម្លៃពេញលេញលើផលប៉ះពាល់
# លើប្រកាសរួមស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស

| | | |
|---|---|---|
| អង្គភាព | ៖ | ក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **បុគ្គលទទួលបន្ទុក** | ៖ | **ឯកឧត្តម ហេង សួរ** |
| **តួនាទី** | ៖ | ប្រធានក្រុមការងារ និងជាអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ |
| **អាស័យដ្ឋាន** | ៖ | អគារលេខ ០៣ មហាវិថីសហព័ន្ធរុស្ស៊ី ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ |
| **ទូរស័ព្ទលេខ** | ៖ | (+855) 12 69 37 77 |
| Email | ៖ | hengsour@yahoo.com |
| គេហទំព័រ | ៖ | www.mlvt.gov.kh or www.ntb.gov.kh |

## អង្គភាព/ស្ថាប័នឆ្លងឯកសារ

១ ឆ្លងយោបល់ពីក្រុមការងារវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

២ ពិគ្រោះយោបល់ពីក្រសួង ស្ថាប័នពាក់ព័ន្ធមានរដ្ឋ និងឯកជន

៣ ឆ្លងយោបល់ចុងក្រោយពីការិយាល័យគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃទីស្តីការគណៈរដ្ឋមន្ត្រី

៤ សុំការឯកភាពពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីពិនិត្យធ្វើការកែសម្រួលប្រកាសនេះ ឡើងវិញ។

## កាលបរិច្ឆេទនៃការរៀបចំ

| | | | |
|---|---|---|---|
| កាលបរិច្ឆេទចាប់ផ្តើម | : | ថ្ងៃទី ១៨ ខែ សីហា | ឆ្នាំ ២០១៤ |
| កាលបរិច្ឆេទបញ្ចប់ | : | ថ្ងៃទី ៣១ ខែ ធ្នូ | ឆ្នាំ ២០១៤ |

# មាតិកា

**ផ្នែកទី១**......4

ខ្លឹមសារសង្ខេប ......4

១. ១. ការកំណត់បញ្ហា ......4

១.២. គោលបំណង ......4

១.៣. ជម្រើសនៃបញ្ញត្តិកម្ម......5

១.៤. ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយកាតព្វកិច្ច និងផលចំណេញ......5

១.៥. កិច្ចពិគ្រោះយោបល់ ......5

១.៦. ការអនុវត្តការតាមដាន និងវាយតម្លៃ......6

១.៧. សន្និដ្ឋាន ......6

**ផ្នែកទី២**......7

ការវាយតម្លៃពេញលេញលើផលប៉ះពាល់......7

លើប្រកាសរួមស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស......7

២. ១. គោលបំណង ......7

២.២. ជម្រើសនៃបញ្ញត្តិកម្ម......7

២.២.១ ប្រកាសរួមស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស ......8

២.២.២ ភាពជាដៃគូរបស់រដ្ឋ និងម្ចាស់សហគ្រាស គ្រឹះស្ថាន និងរោងចក្រ ......8

ក្នុងការបង្កើតគិលានដ្ឋាន......8

២.៣. លទ្ធផលនៃការចុះវាយតម្លៃផលប៉ះពាល់នៃប្រកាសលេខ០៣៣ ......9

២.៣.១ ការកើនឡើងនៃគ្រោះថ្នាក់ការងារ ......9

២.៣.២ ភាពអប្រសិទ្ធភាពនៃការអនុវត្តប្រកាសរួម ......10

២.៣.៤ ភាពខ្វះចន្លោះរបស់អង្គភាពទទួលខុសត្រូវ ......12

២.៣.៥ អាយុកាលនៃប្រកាសរួមលេខ ០៣៣ សកបយ ......13

២.៤ ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយកាតព្វកិច្ច និងផលចំណេញ ......14

២.៤.១. ការកំណត់ភារកិច្ចនិងប្រភេទបន្ទុកចំណាយ ........ 14

២.៥.២. ការកំណត់ប្រភេទនៃផលចំណេញ ........ 17

២.៥.៣. វិសាលភាពនៃជម្រើសនីមួយៗ ........ 18

២.៦. លទ្ធផលនៃកិច្ចពិគ្រោះយោបល់បឋម ........ 18

២.៧. ការអនុវត្ត និងការតាមដាន ........ 21

២.៨. សេចក្តីសន្និដ្ឋាន ........ 21

**ឧបសម្ព័ន្ធ** ........ 24

# ផ្នែកទី១
# ខ្លឹមសារសង្ខេប

ប្រកាសរួម លេខ ៣៣០ សកបយ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស ត្រូវបានរៀបចំឡើងដោយ អតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដោយរួមសហការជាមួយក្រសួងសុខាភិបាល ដើម្បីជំរុញឱ្យហគ្រាស គ្រឹះស្ថាន និងរោងចក្រនិមួយៗ ត្រូវបំពេញកាតព្វកិច្ច និងមានភារកិច្ចលើការជួយថែទាំសុខភាព កាត់បន្ថយគ្រោះថ្នាក់ការងារ ដែលបង្កឡើងធ្វើឲ្យប៉ះពាល់ដល់សុខភាព និងអាយុជីវិតរបស់កម្មករនិយោជិត។

## ១. ១. ការកំណត់បញ្ហា

- ការគ្រោះថ្នាក់ការងារនៅតែបន្តកើតមានពីមួយឆ្នាំទៅមួយឆ្នាំ (គ្រោះថ្នាក់ការងារពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១០ កើនឡើងរហូតដល់ជាង៤០០០ករណី ហើយពីឆ្នាំ២០១០ដល់ឆ្នាំ២០១៣ កំណើនគ្រោះថ្នាក់ការងារនៅរក្សាការកើនឡើងជាង២០០០ ករណីពីមួយឆ្នាំទៅមួយឆ្នាំ)
- ការអនុវត្តប្រកាសនេះមិនទាន់មានប្រសិទ្ធភាពខ្ពស់ (ការរៀបចំមិនទាន់មានគ្រប់ទៅតាមលក្ខណតម្រូវ និងរោងចក្រមួយចំនួន មិនទាន់បានបង្កើតបន្ទប់សង្គ្រោះបឋម....)
- ភាពខ្វះចន្លោះរបស់អង្គភាពទទួលខុសត្រូវ (ការអប់រំផ្សព្វផ្សាយមិនទាន់ទំលំទូលាយ ខ្វះការតាមដាន ត្រួតពិនិត្យ និងគ្មានការពិន័យ....)
- ប្រកាសរួមនេះ មានអាយុកាលជាង១៤ឆ្នាំ ស្ថាប័នទទួលបន្ទុក(អតីតក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា) និងខ្លឹមសារមួយចំនួន មិនទាន់សមស្របទៅនឹងស្ថានភាពបច្ចុប្បន្ន។

## ១.២. គោលបំណង

- កាត់បន្ថយអំពីគ្រោះថ្នាក់ការងារ ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាព ក៏ដូចអាយុជីវិតរបស់កម្មករនិយោជិត តាមរយៈការសង្គ្រោះបឋម ឬព្យាបាលបឋមដល់កម្មករនិយោជិតក្នុងអំឡុងពេលបំពេញការងារ។

## ១.៣. ជម្រើសនៃបញ្ញត្តិកម្ម

តាមរយៈ កិច្ចពិភាក្សាជាច្រើនលើកច្រើនសាររបស់ក្រុមការងារ បានជ្រើសយក **ជម្រើសទី១** នៃប្រកាសរួម ស្តីពីការរៀបចំគិលានដ្ឋាននៅតាមសហគ្រាស គ្រឹះស្ថាន ដែលនិយោជកនីមួយៗ មានភារកិច្ចទទួលខុសត្រូវក្នុងការរៀបចំ និងដាក់ឱ្យដំណើរការនូវបន្ទប់សង្គ្រោះបឋមមួយ នៅតាមទីតាំងសហគ្រាស គ្រឹះស្ថាន និងរោងចក្ររបស់ខ្លួន។

## ១.៤. ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយភាគពាកិច្ច និងផលចំណេញ

ការជ្រើសយកជម្រើសទី១ ដោយបានលើកអំណះអំណាងថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវចំណាយអស់ចំនួន US$ ១៨០.០៣៨ លើការរៀបចំប្រកាសរួម ចូលរួមអប់រំផ្សព្វផ្សាយដល់ម្ចាស់សហគ្រាស គ្រឹះស្ថាន រោងចក្រ គិលានុបដ្ឋាកយិកា គ្រូពេទ្យ និងចំណាយលើការចុះត្រួតពិនិត្យតាមដាន និងវាយតម្លៃ។ ចំណែកភាគីនិយោជក ចំណាយអស់ US$ ៥០.៨១៤.៧១៤ ក្នុងចំណោម សហគ្រាស គ្រឹះស្ថាន និងរោងចក្រចំនួន ១៦០០ ហើយក្នុងរោងចក្រមួយ ត្រូវចំណាយសរុបមានចំនួន US$ ៣១.៧៥៩ លើប្រាក់ខែគិលានុបដ្ឋាកយិកា គ្រូពេទ្យ មូលដ្ឋានឧបករណ៍សម្ភារៈពេទ្យ ថ្នាំពេទ្យ និងដំណើរការបន្ទប់សង្គ្រោះបឋម។ល។ ជាជាងការជ្រើសយកជម្រើសទី២ ដែលថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវចំណាយអស់ US$ ៣៦.០៣២.២១៣ សម្រាប់ការរៀបចំប្រកាសរួម សិក្ខាសាលាពិគ្រោះយោបល់ និងចំណាយលើការចុះត្រួតពិនិត្យតាមដាន និងវាយតម្លៃ។ ចំណែកភាគីនិយោជកវិញ ចំណាយអស់ US$ ១៧.៩១២.៧៩៤ ក្នុងចំណោមសហគ្រាស គ្រឹះស្ថាន និងរោងចក្រចំនួន ១៦០០ ហើយក្នុងរោងចក្រមួយត្រូវចំណាយអស់ចំនួន US$ ១១.១៩៥,៥០ សម្រាប់ចំណាយលើការអប់រំបណ្តុះបណ្តាលជំនាញដល់គិលានុបដ្ឋាកយិកា គ្រូពេទ្យ មូលដ្ឋានឧបករណ៍សម្ភារៈពេទ្យ ថ្នាំពេទ្យ និងដំណើរការបន្ទប់សង្គ្រោះបឋម។ល។

## ១.៥. កិច្ចពិគ្រោះយោបល់

ការសិក្សាស្រាវជ្រាវរកផលប៉ះពាល់ តាមរយៈ ការប្រជុំពិគ្រោះយោបល់ជាមួយមន្ត្រីពាក់ព័ន្ធ កម្មករនិយោជិក និងការចុះជួបដោយផ្ទាល់នៅតាមសហគ្រាស គ្រឹះស្ថាន និងរោងចក្រចំនួន ១២ ក្នុងខេត្តព្រះសីហនុ ខេត្តកោះកុង និងខេត្តបន្ទាយមានជ័យ ដោយទទួលបានលទ្ធផលចម្បងៗដូចខាងក្រោម៖

- គុណភាពខ្លឹមសារ ដែលមានចែងក្នុងប្រកាសរួមនេះ មានលក្ខណៈសមស្រប និងអាចទទួលយកបាន ហើយមានលក្ខណៈស្រដៀងគ្នាជាមួយច្បាប់នៅប្រទេសថៃឡង់ដ៍ ចិន និងជប៉ុនផងដែរ។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរធ្វើការពិនិត្យ និងកែសម្រួលនូវចំណុចមួយចំនួនដែលមានចែងក្នុងប្រកាសរួមនេះ ឱ្យបានស៊ីគ្នាជាមួយស្ថានភាពបច្ចុប្បន្ន។
- ទន្ទឹមនឹងការកែលម្អនូវខ្លឹមសារមួយចំនួនខាងលើ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវពង្រឹង និងពង្រីកនូវយន្តការការងាររបស់ខ្លួនបន្ថែមទៀត។

## ១.៦. ការអនុវត្តការតាមដាន និងវាយតម្លៃ

- ប្រើប្រាស់យន្តការ ដែលមានស្រាប់ គឺក្រុមអធិការកិច្ចរួម និងបន្ថែមបើមានការចាំបាច់
- ចុះត្រួតពិនិត្យតាមដាននិងវាយតម្លៃឱ្យបានទៀងទាត់ជារៀងរាល់ឆ្នាំ នៅក្នុងខែមិថុនា ដោយមានការប្រជុំប្រចាំខែ ត្រីមាស ឆមាស ប្រចាំឆ្នាំ រួមជាមួយរបាយការណ៍ជាក់លាក់។

## ១.៧. សន្និដ្ឋាន

ក្រុមការងារបានពិនិត្យឃើញថា ជម្រើសទីមួយ មានលក្ខណៈសម្បត្តិសមស្រប គ្រប់ជ្រុងជ្រោយ ទាំងខ្លឹមសារ និងនីតិវិធីណែនាំក្នុងការអនុវត្ត។ល។ ពិសេសផលចំណេញ ឬផលប្រយោជន៍ ដែលភាគីទាំងរាជរដ្ឋាភិបាល ក៏ដូចវិស័យឯកជនទទួលបានមានលក្ខណៈសមធម៌៕

# ផ្នែកទី២
# ការវាយតម្លៃពេញលេញលើផលប៉ះពាល់ លើប្រកាសរួមស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស

## ២.១. គោលបំណង

ប្រកាសរួម លេខ ៣៣០ សកបយ ត្រូវរាជរដ្ឋាភិបាលកម្ពុជាបានរៀបចំឱ្យមានបញ្ញត្តិកម្មនេះឡើង ដើម្បីកាត់បន្ថយអំពីគ្រោះថ្នាក់ ការងារ ដែលធ្វើឲ្យប៉ះពាល់ដល់សុខភាព ក៏ដូចអាយុជីវិតរបស់កម្មករនិយោជិត តាមរយៈការផ្តល់សេវាសង្គ្រោះបឋម ឬសង្គ្រោះបន្ទាន់ដល់កម្មករនិយោជិតដែលទទួលរងគ្រោះថ្នាក់ពីការងារ ឬផលប៉ះពាល់នានាពីការងារ និងរួមទាំងជួយពិនិត្យសង្គ្រោះ/ព្យាបាលបឋមដល់កម្មករនិយោជិតដែលមានជម្ងឺផ្សេងៗក្នុងអំឡុងពេលបំពេញការងារផងដែរ។

ម្យ៉ាងវិញទៀត អនុវត្តឱ្យស្របតាមលក្ខខណ្ឌ ស្តីពីការងាររបស់អន្តរជាតិ និងដើម្បីចូលរួមការពារផលប្រយោជន៍របស់កម្មករនិយោជិតឱ្យស្របតាមលក្ខខណ្ឌនានា ដែលអ្នកបញ្ជាទិញ និងដៃគូអភិវឌ្ឍន៍នានាបានទាមទារ ក៏ដូចជាការគោរព និងផ្តល់កិត្តិយស់ឱ្យគ្នាទៅវិញទៅមក រវាងកម្មករនិយោជិត និងនិយោជក និងជាពិសេស ដើម្បីស្របតាមតួនាទី និងបេសកកម្មរបស់ស្ថាប័នទទួលខុសត្រូវរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចាំបាច់ត្រូវការធ្វើការកែសម្រួលប្រកាសរួមនេះ ឱ្យសមស្របតាមស្ថានភាពបច្ចុប្បន្នរបស់ព្រះរាជាណាចក្រកម្ពុជា។

## ២.២. ជម្រើសនៃបញ្ញត្តិកម្ម

ភាពខ្វះចន្លោះកន្លងមក ដែលសហគ្រាស គ្រឹះស្ថាន និងរោងចក្រមួយចំនួនធំមិនបានអនុវត្តតាម ដោយការធ្វេសប្រហែសរបស់និយោជក ឬអាចនិយាយម្យ៉ាងវិញទៀតថា និយោជកមួយចំនួន មិនសូវគោរពច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដោយឆ្លៀតឱកាសទាញយកផលចំណេញតាមរយៈ ការកេងប្រវ័ញ្ចន៍ និងហ៊ានប្រព្រឹត្តបទល្មើសផ្សេងៗតាមលទ្ធភាពដែលខ្លួនអាចធ្វើបាន។ ពិសេសការគិតឃើញរបស់និយោជកក្នុងការរៀបចំគិលានដ្ឋានសហគ្រាស នៅតាមសហគ្រាស គ្រឹះស្ថាន និងរោងចក្រ បានធ្វើឱ្យពួកគាត់ត្រូវការចំណាយច្រើនទាំងការសាងសង់បន្ទប់ ឬជួលបន្ទប់បន្ថែម សម្រាប់រៀបចំជាបន្ទប់សង្គ្រោះបឋម ចំណាយលើការបំពាក់ឧបករណ៍សម្ភារៈពេទ្យ ចំណាយលើថ្នាំពេទ្យ ចំណាយលើការជួលគិលានុបដ្ឋាយិកា និងគ្រូពេទ្យប្រចាំការ។ល។

ហេតុដូចនេះ ក្រុមការងារវាយតម្លៃផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរកឃើញនូវជម្រើស ២ (ពីរ) ជាជំនួយស្មារតីសម្រាប់ជួយឱ្យរាជរដ្ឋាភិបាល និងក៏ដូចជាការជួយឱ្យនិយោជកធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសយកជម្រើសឬវិធីសាស្ត្រណាមួយ ដែលមានភាពសមធម៌ ហើយអាចធ្វើឱ្យភាគីទាំងពីរទទួលយកបានដោយមានអារម្មណ៍រីករាយ និងចូលរួមទទួលខុសត្រូវទាំងអស់គ្នា។ ជម្រើសទាំងពីរនោះ រួមមាន៖

### ២.២.១ ប្រកាសរួមស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស

សហគ្រាស គ្រឹះស្ថាន និងរោងចក្រនីមួយៗ ត្រូវគោរព និងអនុវត្តតាមខ្លឹមសារទាំងស្រុង ដែលមានចែងក្នុងប្រកាសរួមលេខ ៣៣០ សកបយ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស។ ប៉ុន្តែក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវធ្វើការកែលំអចំណុចមួយចំនួន ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ខ្លួនឱ្យស្របតាមភារកិច្ច និងការទទួលខុសត្រូវ ដែលមានចែងក្នុងអនុក្រឹត្យលេខ ២៨៣ អនក្រ បក ចុះថ្ងៃទី៨១ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីដំណើរការនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

និយោជកនីមួយៗ មានភារកិច្ចទទួលខុសត្រូវក្នុងការរៀបចំបន្ទប់សង្គ្រោះបឋមមួយនៅតាមទីតាំងសហគ្រាស គ្រឹះស្ថាន និងរោងចក្ររបស់ខ្លួនស្របតាមការកំណត់ដែលមានចែងក្នុងច្បាប់ស្តីពីការងារ។ តាមបន្ទប់សង្គ្រោះបឋមនីមួយៗ ត្រូវបំពាក់នូវឧបករណ៍សម្ភារៈពេទ្យ ថ្នាំពេទ្យ ជួលគិលានុបដ្ឋាយិកា និងគ្រូពេទ្យប្រចាំការតាមថ្ងៃនីមួយៗ យ៉ាងហោចណាស់ឱ្យបានសមស្របដូចខ្លឹមសារដូចមានចែងក្នុងប្រកាសរួមលេខ ៣៣០ សកបយ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស។ ដូចនេះ ម្ចាស់សហគ្រាស គ្រឹះស្ថាន និងរោងចក្រនីមួយៗ ត្រូវធានាខុសត្រូវរាល់ការចំណាយសម្រាប់ដំណើរការបន្ទប់សង្គ្រោះបឋមឱ្យបានល្អ ក្នុងការជួយសង្គ្រោះបឋមដល់កម្មករនិយោជិតរបស់ខ្លួននៅពេលជួបគ្រោះថ្នាក់ការងារកើតឡើង។

### ២.២.២ ភាពជាដៃគូរបស់រដ្ឋ និងម្ចាស់សហគ្រាស គ្រឹះស្ថាន និងរោងចក្រក្នុងការបង្កើតគិលានដ្ឋាន

ជម្រើសនេះ គឺជាការចូលរួមរបស់រាជរដ្ឋាភិបាលក្នុងសកម្មភាពរៀបចំគិលានដ្ឋានសហគ្រាសសម្រាប់សង្គ្រោះបឋមនៅពេលកម្មករនិយោជិតនៅតាមសហគ្រាស គ្រឹះស្ថាន និងរោងចក្រនីមួយៗជួបនូវឧបទ្ទវហេតុគ្រោះថ្នាក់ការងារ ដោយប្រការណាមួយ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនៃព្រះ

រាជាណាចក្រកម្ពុជា ចូលរួមក្នុងការផ្គត់ផ្គង់គិលានុបដ្ឋាក-យិកា គ្រូពេទ្យ និងបូករួមជាមួយប្រាក់ខែ។ រីឯរាល់ការចំណាយនានាទៅលើការបណ្តុះបណ្តាល ឬបំប៉ននូវសមត្ថភាពបន្ថែមរបស់គិលានុបដ្ឋាក-យិកា និងគ្រូពេទ្យ គឺជាបន្ទុកចំណាយរបស់និយោជកនីមួយៗ។

បន្ថែមលើការចំណាយក្រៅពីប៉ុន្មានចំនុចខាងលើ និយោជក មានភារកិច្ច និងកាតព្វកិច្ចក្នុងការទទួលខុសត្រូវរាល់ការចំណាយសម្រាប់សាងសង់/ជួលបន្ទប់សង្គ្រោះបឋម ការចំណាយសម្រាប់ពាក់ឧបករណ៍សម្ភារៈបរិក្ខារពេទ្យ គ្រឿងសង្ហារឹម ថ្នាំពេទ្យ តំហែទាំ និងចំណាយដំណើរការការងាររដ្ឋបាលសម្រាប់ដំណើរការសង្គ្រោះបឋម។ល។

## ២.៣. លទ្ធផលនៃការចុះវាយតម្លៃផលប៉ះពាល់នៃប្រកាសលេខ០៣៣

### ២.៣.១ ការកើនឡើងនៃគ្រោះថ្នាក់ការងារ

តាមរយៈ ការសិក្សាស្រាវជ្រាវនៅតាមសហគ្រាស គ្រឹះស្ថាន និងរោងចក្ររបស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ កាលពីឆ្នាំ២០១១ បានបង្ហាញឱ្យឃើញថា ចំនួនសហគ្រាស គ្រឹះស្ថានដែលបានប្រើប្រាស់កម្លាំងពលកម្ម ចាប់ពី ៥០នាក់ឡើង មានរហូតជាង ១៦២១ សហគ្រាស ដែលកំពុងប្រកបអាជីវកម្មរបររកស៊ីចិញ្ចឹមជីវិតក្នុងវិស័យផ្សេងៗគ្នា[1]។

ដោយឡែក តាមរយៈរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងឆ្នាំ ២០១៤ បានបង្ហាញឱ្យឃើញថា កំណើនអ្នកវិនិយោគិនទាំងក្នុងស្រុក និងក្រៅស្រុក ដែលវិនិយោគភាគច្រើនលើវិស័យវាយនភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើង។ បើគិតចាប់ពីឆ្នាំ ២០០៩-២០១៣ មានចំនួនសហគ្រាស គ្រឹះស្ថាន បានកើនឡើងពីចំនួន ៩៦៨ ដល់ ៩៦០ និងបានប្រើប្រាស់កម្មករនិយោជិតមានការកើនឡើងពី៣៣២ ៨៣៧នាក់ (២០០៩) រហូតដល់ ៦២៨ ១៦៦នាក់(២០១៣)[2] ។

ការរីកចម្រើន ខាងវិស័យវាយនភ័ណ្ឌកាត់ដេរ សម្លៀកបំពាក់ និងផលិតស្បែកជើងបានធ្វើឱ្យមានកំណើនទាំងចំនួនសហគ្រាស គ្រឹះស្ថាន និងរោងចក្រ ពិសេសកំណើនចំនួនកម្មករនិយោជិតពីមួយឆ្នាំទៅមួយឆ្នាំ។ ការកើនឡើង នៃចំនួនកម្មករនិយោជិត បានធ្វើឱ្យជួបនូវបញ្ហាអំពីគ្រោះថ្នាក់ពីការងារជារៀងរាល់ឆ្នាំ។ តាមរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជា

[1] ជំរឿនសហគ្រាសឆ្នាំ២០១១ របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ

[2] ផែនការយុទ្ធសាស្ត្រ ២០១៤-២០១៨, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ជីវៈ ដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ ២០១៤-២០១៨ បានបង្ហាញឱ្យឃើញថា គិតចាប់ពីឆ្នាំ ២០០៩-២០១៣ មានហានិភ័យការងារចំនួនសរុប ៥៧ ០៦៧នាក់ ក្នុងនោះ មានគ្រោះថ្នាក់ការងារចំនួន ៥៤ ៧៤៣នាក់ និងមិនមែនគ្រោះថ្នាក់ការងារចំនួន ២ ០៧៩នាក់[1]។

## ២.៣.២ ភាពអប្រសិទ្ធភាពនៃការអនុវត្តប្រកាសរួម

បន្ទាប់ពី ប្រកាសរួម លេខ ៣៣០ សកបយ បានដាក់ឱ្យដំណើរការ អស់រយៈពេលជាង១៨ឆ្នាំមកនេះ សហគ្រាស គ្រឹះស្ថាន និងរោងចក្រមួយចំនួន មិនទាន់បានអនុវត្តតាមខ្លឹមសារ ដែលមានចែងក្នុងប្រកាសរួមនេះនៅឡើយ។ តាមរយៈ ការសិក្សាស្រាវជ្រាវរបស់ក្រុមការងារអនុវត្តគម្រោងវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយមន្ត្រី និងថ្នាក់ដឹកនាំរបស់ការិយាល័យវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ២០-៣១ ខែកក្កដា ឆ្នាំ២០១៤ នៅខេត្តចំនួន៣ គឺខេត្តព្រះសីហនុ ខេត្តកោះកុង និងខេត្តបន្ទាយមានជ័យ ដែលបានអនុវត្តលើសហគ្រាស គ្រឹះស្ថាន និងរោងចក្រចំនួន១២ ដោយជ្រើសរើសយករោងចក្រចំនួន ៤ ក្នុងមួយខេត្តៗ។ ក្នុងចំណោមសហគ្រាស គ្រឹះស្ថាន និងរោងចក្រទាំង១២នោះ បានកំពុងធ្វើអាជីវកម្មផលិតស្រាបៀរចំនួន ១ កន្លែង ផលិតស្ករអំពៅចំនួន ១ កន្លែង ផលិតបរិក្ខារអគ្គិសនី និងអេឡិចត្រូនិចចំនួន ១ កន្លែង ផលិតសម្ភារៈកីឡាចំនួន ១ កន្លែង ផលិតប្រអប់សម្រាប់ដាក់គ្រឿងអលង្ការចំនួន ១កន្លែង និងកាត់ដេរសំលៀកបំពាក់ចំនួន ៧កន្លែង។

ជាលទ្ធផល ក្រុមការងារ បានរកឃើញថា មានរោងចក្រចំនួន ៣ ក្នុងចំណោមទាំង ១២ បានរៀបចំបន្ទប់សង្គ្រោះបឋម មានជាលក្ខណៈស្តង់ដា ដោយមានការរៀបចំបានល្អ ទីតាំងស្ងាត់ល្អ ឆ្ងាយពីកន្លែងមានសម្លេង មានអនាម័យល្អ មានគ្រូពេទ្យ និងគិលានុបដ្ឋាក-យិកាប្រចាំការ មានឧបករណ៍សម្ភារៈពេទ្យគ្រប់គ្រាន់ បានរៀបចំទុកដាក់ឧបករណ៍សម្ភារៈ បានត្រឹមត្រូវ និងតាមលំដាប់លំដោយ និងមានថ្នាំពេទ្យ ស្របទៅតាមនិយាមដែលបានកំណត់ក្នុងប្រកាសរួមនោះ។

រោងចក្រចំនួន ៧ ទៀត មិនសូវមានលក្ខណៈសមស្រប ដោយការរៀបចំ ខ្វះសណ្តាប់ធ្នាប់ក្នុងបន្ទប់ មិនមានអនាម័យល្អ សម្ភារៈអនាម័យនៅរាយបាយក្នុងបន្ទប់ រោងចក្រខ្លះ មានគ្រូពេទ្យប្រចាំការ រោងចក្រខ្លះទៀត មានគិលានុបដ្ឋាក-យិកាប្រចាំការ ខ្វះឧបករណ៍សម្ភារៈពេទ្យគ្រប់គ្រាន់

មានថ្នាំពេទ្យបន្តិចបន្តួចដាក់ក្នុងទូរ។ រីឯទីតាំងបន្ទប់សង្គ្រោះបឋម ស្ថិតនៅជាប់កន្លែងធ្វើការរបស់កម្មករនិយោជិត ឮសូរសំលេងសកម្មភាពការងារក្នុងរោងចក្រ បន្ទប់តូចចង្អៀត មានក្លិនរបស់វត្ថុធាតុដើម ដូចជា ក្រណាត់ ជ័រការ។ល។

រោងចក្រចំនួន ១ មិនបានរៀបចំឱ្យមានបន្ទប់សង្គ្រោះបឋម ដោយមូលហេតុថា មិនបានដឹងអំពីប្រកាសរួមនេះ ព្រោះរោងចក្រនេះ មានការផ្លាស់ប្តូរបុគ្គលិករដ្ឋបាលច្រើនដងពេក។ ម្យ៉ាងវិញទៀត ទីតាំងរបស់រោងចក្រនៅឆ្ងាយពីទីតាំងប្រជុំជន លំបាកការធ្វើដំណើរ/មធ្យោបាយធ្វើដំណើរ បញ្ហាហូបចុក ស្នាក់នៅ ក៏ដូចសុវត្ថិភាពផ្ទាល់ខ្លួន។ល។ បញ្ហាទាំងនេះ បានជំរុញធ្វើឱ្យបុគ្គលិកភាគច្រើន មិនចង់ធ្វើការនៅទីនេះបានយូរ។ អ្វីដែលពិសេសទៀតនោះ មិនដែលមានមន្ត្រីតំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ឬ មន្ត្រីមកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចុះមកត្រួតពិនិត្យ និងផ្តល់អនុសាសន៍ដល់រោងចក្រដែរ។

រីឯរោងចក្រ ១ ទៀត បានយកកន្លែងធ្វើការរដ្ឋបាលជាកន្លែង សម្រាប់សង្គ្រោះបឋម គ្មានឧបករណ៍សម្ភារៈពេទ្យ មានថ្នាំពេទ្យបន្តិចបន្តួចដាក់ក្នុងទូរ។ រីឯទីតាំងបន្ទប់ស្ថិតនៅជាប់កន្លែងធ្វើការរបស់កម្មករនិយោជិត ឮសូរសំលេង បន្ទប់តូចចង្អៀត មានក្លិនរបស់វត្ថុធាតុដើម ដូចជា ជ័រការជាដើម។ ពិសេសទៀតនោះ មានបុគ្គលិករដ្ឋបាលម្នាក់ បានដើរតួជាគ្រូពេទ្យផង និងជាគិលានុបដ្ឋាក-យិកាផង។ ក្រុមការងារ មានសំណួរមួយចំនួនពាក់ព័ន្ធបញ្ហាទាំងនេះ តំណាងរោងចក្របានអះអាងថា រោងចក្រទើបបង្កើតក្នុងឆ្នាំ ២០១២ ហើយបញ្ហាគ្រោះថ្នាក់ការងារ មានចំនួនតិចតួច ជារៀងរាល់ឆ្នាំ មានអ្នកគ្រោះថ្នាក់ការងារត្រឹមចំនួន ២ទៅ៣នាក់ ប៉ុណ្ណោះ មិនមានច្រើនទេ។

បញ្ហាមួយចំនួនទៀត ដែលក្រុមការងារបានពិនិត្យឃើញ ហើយគិតថា មានផលប៉ះពាល់អារម្មណ៍របស់និយោជិត ក្នុងការរៀបចំឱ្យមានបន្ទប់សង្គ្រោះបឋម នៅតាមសហគ្រាស គ្រឹះស្ថាន និងរោងចក្រនីមួយៗ គឺបានធ្វើឱ្យប៉ះពាល់ដល់ការចំណាយរបស់និយោជកក្នុងមួយឆ្នាំៗ ដោយពួកគាត់គិតថា ត្រូវចំណាយលើការជួលគ្រូពេទ្យ គិលានុបដ្ឋាក-យិកា ការទិញឧបករណ៍សម្ភារៈពេទ្យ ថ្នាំពេទ្យ និងរបស់របរប្រើប្រាស់មួយចំនួនទៀត។ ការរៀបចំឱ្យមានគិលានដ្ឋានសហគ្រាសនេះ បានធ្វើឱ្យប៉ះពាល់ដល់ទីតាំងរបស់សហគ្រាស គ្រឹះស្ថាន និងរោងចក្រ ព្រោះភាគច្រើន នៃទីតាំងគឺនិយោជកបានជួលគេ។ លំបាករកគិលានុបដ្ឋាក-យិកា និងគ្រូពេទ្យ ដែលមានសមត្ថភាពគ្រប់គ្រាន់ និងគុណភាពមកបម្រើការក្នុងបន្ទប់សង្គ្រោះបឋម ដែលមានប្រាក់ឈ្នួលទាប។ ម្យ៉ាងវិញទៀត សហគ្រាស គ្រឹះស្ថាន និងរោងចក្រមួយចំនួនទៀត បានអះអាងថា មានទីតាំងស្ថិតនៅក្បែរមជ្ឈមណ្ឌលសុខភាពឃុំ/សង្កាត់ហើយ អាចនឹងមានសុវត្ថិភាព ឬនិងអាចបញ្ជូនទៅសង្គ្រោះបន្ទាន់បានទាន់ពេលវេលាទៀតផង។

## ២.៣.៤ ភាពខ្វះចន្លោះរបស់អង្គភាពទទួលខុសត្រូវ

ទន្ទឹមនេះ ការពិនិត្យឃើញនូវបញ្ហាមួយចំនួន នៅក្នុងការប្រតិបត្តិរបស់វិស័យឯកជន ក្រុមការងារ ក៏បានពិនិត្យឃើញថា ស្ថាប័នរបស់រដ្ឋដែលទទួលខុសត្រូវពាក់ព័ន្ធនឹងបញ្ញត្តិកម្មនេះ ក៏នៅការអនុវត្តខ្វះចន្លោះប្រហោងមួយចំនួនដែរ ដើម្បីធ្វើឱ្យការប្រតិបត្តិនូវខ្លឹមសារប្រកាសរួមនេះ មានប្រសិទ្ធភាពខ្ពស់។

បញ្ហាមួយចំនួន ដែលក្រុមការងារវាយតម្លៃនៃផលប៉ះពាល់លើលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានពិនិត្យឃើញរួមមាន៖

១) កង្វះនូវការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងដឹងឮឱ្យបានជ្រួតជ្រាបដល់ក្រុមគោលដៅ។ អង្គភាពទទួលខុសត្រូវភាគច្រើន បានផ្សព្វផ្សាយ តាមរយៈ វិទ្យុ ទូរទស្សន៍ និងកាសែត ហើយការផ្សព្វផ្សាយនេះទៀតសោត ភាគច្រើនធ្វើឡើងនៅពេលបញ្ញត្តិកម្មដាក់ឱ្យអនុវត្តដំបូង និងមិនសូវបានញឹកញាប់ទេ ដោយសារការផ្សព្វផ្សាយរបៀបនេះ ត្រូវការចំណាយធនធានច្រើន។ រីឯការផ្សព្វផ្សាយដោយផ្ទាល់នោះ អង្គភាពទទួលបន្ទុកមិនសូវបានធ្វើទេ ពិសេស មិនសូវដែលបានចុះជួបអប់រំ និងណែនាំដោយផ្ទាល់ជាមួយអតិថិជន ឬអ្នកប្រតិបត្តិបញ្ញត្តទេ ព្រោះពាក់ព័ន្ធមធ្យោបាយធ្វើដំណើរ ការចំណាយហូបចុក មានទាំងការស្នាក់នៅទៀត បើផ្លូវឆ្ងាយ។

២) រាល់សកម្មភាពនីមួយៗ អង្គភាពទទួលបន្ទុកមិនសូវបានយកចិត្តទុកដាក់ក្នុងការត្រួតពិនិត្យតាមដាន និងវាយតម្លៃទេ មិនដឹងថារាល់ការអនុវត្តមានផលប៉ះពាល់អ្វីខ្លះ និងមានប្រសិទ្ធភាពប៉ុណ្ណា។ អង្គភាពទទួលខុសត្រូវការងារ ក៏ដូចអ្នកទទួលខុសត្រូវមិនបានដឹងថា មានបញ្ហាខ្វះខាតត្រង់ចំណុចណាខ្លះនៅក្នុងការអនុវត្តការងារ។ ពេលខ្លះបានដឹងពីបញ្ហា ប៉ុន្តែអ្នកទទួលខុសត្រូវ ក៏ដូចអង្គភាពទទួលខុសត្រូវ គ្មានវិធានការដោះស្រាយ និងធ្វើឲ្យប្រសើរឡើង។

៣) វិធានការដាក់ពិន័យ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនទាន់បានអនុវត្តឱ្យបានពេញលេញលើសហគ្រាស គ្រឹះស្ថាន និងរោងចក្រណាមួយដែលមិនគោរព និងប្រតិបត្តិតាមបញ្ញត្តកម្មនេះ។ កន្លងមក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តែងមានការយោគយល់ដោយអនុវត្តនូវនយោបាយធ្វើការសម្របសម្រួល។ សហគ្រាស គ្រឹះស្ថាន និងរោងចក្រណាមួយចំនួន ដែលបានធ្វើខុសកន្លងមក នៅតែហ៊ានប្រព្រឹត្តខុសបន្តទៀត។ ការធ្វើបែបនេះ បានជំរុញ និងលើកទឹកចិត្តឱ្យសហគ្រាស គ្រឹះស្ថាន និងរោងចក្រមួយចំនួន ហ៊ានប្រព្រឹត្តបទល្មើសនឹងបញ្ញត្តកម្មនេះ។

## ២.៣.៥ អាយុកាលនៃប្រកាសរួមលេខ ០៣៣ សកបយ

ក្រុមការងារវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានកតិយុត្តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានពិនិត្យឃើញថា លិខិតបទដ្ឋានគតិយុត្តនីមួយៗ មានអាយុកាលរយៈពេលផ្សេងៗគ្នា ហើយខ្លះមានអាយុកាលរហូតជាង ១០ឆ្នាំ នៅតែមិនទាន់មានការធ្វើវិសោធនកម្មឡើងវិញ។ ដោយឡែក **ប្រកាសរួមលេខ ៣៣០ សកបយ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាសមានអាយុកាលជាង ១៨ឆ្នាំ** ដែលរៀបចំឡើង ដោយអតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទានៅតែមានសុពលភាពក្នុងការអនុវត្តរហូតដល់សព្វថ្ងៃ។

ម្យ៉ាងវិញទៀត ក្នុងនីតិកាលទី៣ នៃរដ្ឋសភាព ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានបង្កើតឡើង ដោយព្រះរាជក្រមលេខ នស/រកត/០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអនុក្រឹត្យលេខ ២៨៣ អនក្រ បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ជំនួសដោយអនុក្រឹត្យលេខ៥២អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ដែលត្រូវបាននិរាសករណ៍) ហើយមានបេសកកម្មដឹកនាំ និងគ្រប់គ្រងវិស័យការងារ និងវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ។ ការទទួលខុសត្រូវវិស័យការងារ គឺមិនមែនស្ថិតក្រោមការដឹកនាំ និងគ្រប់គ្រងដោយក្រសួងសង្គមកិច្ច យុវនិតិសម្បទា និងអតីតយុទ្ធជនពេលបច្ចុប្បន្ននេះទេ។

រីឯខ្លឹមសារមួយចំនួន ដែលបានចែងក្នុងប្រកាសរួមលេខ ៣៣០ សកបយ ដូចជា ប្រការ ១ កថាខ័ណ្ឌទី ២ ស្តីពីការដាក់ឱ្យគិលានដ្ឋានអចិន្ត្រៃយ៍នេះ ស្ថិតនៅក្រោមអំណាចនៃការត្រួតពិនិត្យរបស់នាយកដ្ឋានពេទ្យការងារ នៃអតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា គឺខុសពីការពិត ដែលរាជរដ្ឋាភិបាលបានប្រគល់អាណត្តិនៃការទទួលខុសត្រូវលើការងារនេះ មកឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាអ្នកទទួលបន្ទុក។

***សំគាល់:***

**១) បទដ្ឋានគតិយុត្តពាក់ព័ន្ធ:**

- *ច្បាប់ស្តីពីការងារ ក្នុងជំពូកទី៨ បានចែងអំពីអនាម័យនិងសន្តិសុខនៃកម្មករនិយោជិត ក្នុងមាត្រា ២៣៨ នៃផ្នែកទី ៣ ស្តីពីសេវាពេទ្យការងារ បានតម្រូវឲ្យសហគ្រាស គ្រឹះស្ថាន និង រោងចក្រតាមវិស័យដែលមានចែងក្នុងមាត្រា ១ ត្រូវរៀបចំឲ្យមានការព្យាបាលបឋមសម្រាប់កម្មករនិយោជិតរបស់ខ្លួន*

*ហើយមាត្រា ២៤២ បានកំណត់ឲ្យសហគ្រាស គ្រឹះស្ថាន និងរោងចក្រណាដែលប្រើកម្មករនិយោជិតយ៉ាងតិច ៥០នាក់ ត្រូវមានគិលានដ្ឋានអចិន្ត្រៃយ៍មួយស្ថិតនៅក្នុងទីតាំងរបស់ខ្លួន។*

- *ប្រកាសរួមលេខ ១៣៩ សកបយ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០១ ស្តីពីលក្ខខណ្ឌនិងបេសកកម្មសេវាពេទ្យសហគ្រាសបន្ថែមដែលបានរៀបចំឡើងដោយអតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។*
- *ប្រកាសលេខ ៣០៧ កប/ប្រក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌអនាម័យ និងសន្តិសុខការងារក្នុងរោងចក្រកាត់ដេរសំលៀកបំពាក់ និងដេរស្បែកជើង ក្នុងគោលបំណងពង្រឹងការអនុវត្តន៍ការផ្តល់សេវាសុខភាពដល់កម្មករនិយោជិតកាន់តែប្រសើរដែលបានរៀបចំឡើងដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។*

២) ផលប៉ះពាល់នៃប្រកាសលេខ ៣៣០ សកបយ

- *យោងតាមខ្លឹមសារដែលមានចែងក្នុងប្រកាសរួមលេខ ៣៣០ សកបយ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាសនេះ ក្រុមការងារវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានរបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានពិនិត្យឃើញថា មិនមានប្រការណាមួយដែលធ្វើឲ្យមានផលអវិជ្ជមាន ឬផលប៉ះពាល់ដល់ការប្រកួតប្រជែងទេ ទោះជាការប្រកួតប្រជែងក្នុងស្រុក ក៏ដូចការប្រកួតប្រជែងក្នុងតំបន់ ឬជាលក្ខណៈសកលផងដែរ។*

## ២.៤ ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយភាគព្វកិច្ច និងផលចំណេញ

### ២.៤.១. ការកំណត់ភារកិច្ចនិងប្រភេទបន្ទុកចំណាយ

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| សំណើបញ្ញត្តិកម្ម: ……… | | |
| ជម្រើសទី១: …………… | - បន្ទុកចំណាយលើដំណើរការតាក់តែងប្រកាសនិងពិគ្រោះយោបល់<br>- បន្ទុកចំណាយលើការបោះពុម្ពអាជ្ញាប័ណ្ណ<br>- បន្ទុកចំណាយលើការរក្សាទុកឯកសារ | - បន្ទុកចំណាយលើដំណើរការតាក់តែងប្រកាស (ពិគ្រោះយោបល់)<br>- បន្ទុកចំណាយលើការបង់អាជ្ញាប័ណ្ណ<br>- បន្ទុកចំណាយលើការជួលគិលានុប្បដ្ឋាក-យិកានិងគ្រូពេទ្យ<br>- បន្ទុកចំណាយលើការបណ្តុះបណ្តាលនិងបំប៉នសមត្ថភាព |

| | | |
|---|---|---|
| | - បន្ទុកចំណាយលើការបោះពុម្ព និងផ្សព្វផ្សាយ<br>- បន្ទុកចំណាយលើការពង្រឹងការអនុវត្ត (ត្រួតពិនិត្យ តាមដាន និងវាយតម្លៃ។ល។) | - បន្ទុកចំណាយលើការទិញឧបករណ៍សម្ភារៈ បរិក្ខារពេទ្យផ្សេងៗ គ្រឿងសង្ហារឹម ថ្នាំពេទ្យសម្រាប់សង្គ្រោះបឋម<br>- បន្ទុកចំណាយលើការដឹកជញ្ជូនសង្គ្រោះបឋម<br>- បន្ទុកចំណាយលើបដិសណ្ឋារកិច្ច<br>- ឬបន្ទុកចំណាយលើការជួលទីតាំង<br>- បន្ទុកចំណាយផ្សេងៗ |
| ជម្រើសទី២:<br>………… | - បន្ទុកចំណាយលើដំណើរការតាក់តែងប្រកាស និងពិគ្រោះយោបល់<br>- បន្ទុកចំណាយលើការជួលគិលានុបដ្ឋាក-យិកា និងគ្រូពេទ្យ<br>- បន្ទុកចំណាយលើការបោះពុម្ពអាជ្ញាប័ណ្ណ<br>- បន្ទុកចំណាយលើការរក្សាទុកឯកសារ<br>- បន្ទុកចំណាយលើការបោះពុម្ព និងផ្សព្វផ្សាយ<br>- បន្ទុកចំណាយលើការពង្រឹងការអនុវត្ត | - បន្ទុកចំណាយលើការពិគ្រោះយោបល់ក្នុងការតាក់តែងប្រកាស<br>- បន្ទុកចំណាយលើដំណើរការបណ្ដុះបណ្ដាល<br>- បន្ទុកចំណាយលើការបង់អាជ្ញាប័ណ្ណ<br>- បន្ទុកចំណាយលើការទិញឧបករណ៍សម្ភារៈ បរិក្ខារពេទ្យផ្សេងៗ គ្រឿងសង្ហារឹម ថ្នាំពេទ្យសម្រាប់សង្គ្រោះបឋម<br>- បន្ទុកចំណាយលើការដឹកជញ្ជូនសង្គ្រោះបឋម<br>- បន្ទុកចំណាយលើបដិសណ្ឋារកិច្ច<br>- បន្ទុកចំណាយលើការជួលទីតាំង<br>- បន្ទុកចំណាយលើការពង្រឹងការ អនុវត្ត<br>- បន្ទុកចំណាយផ្សេងៗ |

## ក. តារាងបន្ទុកចំណាយសម្រាប់ជម្រើសទី ១

| លរ | **បរិយាយ** | បន្ទុកចំណាយរបស់រាជរដ្ឋាភិបាល | បន្ទុកចំណាយរបស់ធុរកិច | ចំណាយសរុបតាមផ្នែក |
|---|---|---|---|---|
| ១ | ការរៀបចំសេចក្ដីព្រាង | $ 2,813 | $ 00 | $ 2,813 |
| ២ | ការពិគ្រោះយោបល់ | $ 10,625 | $ 8,314 | $ 18,939 |

| | | | | |
|---|---|---|---|---|
| ៣ | ការអប់រំ | $ 00 | $ 00 | $ 00 |
| ៤ | លិខិតអនុញ្ញាត ឬផ្តល់អាជ្ញាប័ណ្ណ | $ 8,000 | $ 80,000 | $ 88,000 |
| ៥ | ការចំណាយផ្ទាល់ | $ 00 | $ 45,862,400 | $ 45,862,400 |
| ៦ | ការបញ្ចូលទិន្នន័យ/រក្សាទុកឯកសារ | $ 900 | $ 00 | $ 900 |
| ៧ | ការបោះពុម្ព និងផ្សព្វផ្សាយ | $ 9,700 | $ 00 | $ 9,700 |
| ៨ | ការដាក់ឲ្យប្រតិបត្តិបញ្ញត្ត | $ 148,000 | $ 64,000 | $ 212,000 |
| ៩ | ការចំណាយផ្សេងៗ | $ 00 | $ 4,800,000 | $ 4,800,000 |
| | **សរុបរួម** | **$ 180,038** | **$ 50,814,714** | **$ 50,994,752** |
| បន្ទុកចំណាយរបស់សហគ្រាសមួយ | | | **$ 31,759** | |

## ខ. តារាងបន្ទុកចំណាយសម្រាប់ជម្រើសទី ២

| លរ | **បរិយាយ** | បន្ទុកចំណាយរបស់ រាជរដ្ឋាភិបាល | បន្ទុកចំណាយរបស់ធុរកិច | ចំណាយសរុបតាមផ្នែក |
|---|---|---|---|---|
| ១ | ការរៀបចំសេចក្តីព្រាង | $ 2,813 | $ 00 | $ 2,813 |
| ២ | ការពិគ្រោះយោបល់ | $ 10,625 | $ 8,314 | $ 18,939 |
| ៣ | ការអប់រំ | $ 00 | $ 3,040,000 | $ 3,040,000 |
| ៤ | លិខិតអនុញ្ញាត ឬផ្តល់អាជ្ញាប័ណ្ណ | $ 8,000 | $ 80,000 | $ 88,000 |
| ៥ | ការចំណាយផ្ទាល់ | $ 35,942,400 | $ 9,920,000 | $ 45,862,400 |
| ៦ | ការបញ្ចូលទិន្នន័យ/រក្សាទុកឯកសារ | $ 675 | $ 480 | $ 1,155 |
| ៧ | ការបោះពុម្ព និងផ្សព្វផ្សាយ | $ 9,700 | $ 00 | $ 9,700 |
| ៨ | ការដាក់ឲ្យប្រតិបត្តិបញ្ញត្ត | $ 58,000 | $ 64,000 | $ 122,000 |
| ៩ | ការចំណាយផ្សេងៗ | $ 00 | $ 4,800,000 | $ 4,800,000 |
| | **សរុបរួម** | **$ 36,032,213** | **$ 17,912,794** | **$ 53,945,007** |
| បន្ទុកចំណាយរបស់សហគ្រាសមួយ | | | **$ 11,195.50** | |

## ២.៥.២. ការកំណត់ប្រភេទនៃផលចំណេញ

| ជម្រើស | ប្រភេទនៃផលចំណេញ |
| --- | --- |
| សំណើបញ្ញត្តិកម្ម: | ? |
| ជម្រើសទី១: ………. | -ធ្វើឲ្យមានសេវាសុខភាព មាននៅតាមសហគ្រាស គ្រឹះស្ថាន និងរោងចក្រនិមួយៗ សម្រាប់សង្គ្រោះបឋមដល់បញ្ហាសុខភាពរបស់កម្មករនិយោជិត និងនិយោជក។<br>-គ្រោះថ្នាក់ការងារ នៅតាមបណ្តាសហគ្រាស គ្រឹះស្ថាន និងរោងចក្រនិមួយៗ ត្រូវបានកាត់បន្ថយតាមរយៈការប្រើប្រាស់សេវាសង្គ្រោះបឋម។<br>-ផលិតភាពរបស់កម្មករនិយោជិត មានលំនឹងថេរ ឬអាចការកើនឡើង បើគ្មានបញ្ហាសុខភាព ឬគ្រោះថ្នាក់ការងារណាមួយ កើតឡើងធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់កម្មករនិយោជិត។ ដូចនេះ និយោជកនឹងទទួលបានប្រាក់ចំណូលកើនឡើង។<br>-ធ្វើឱ្យលក្ខខណ្ឌការងារកាន់តែល្អប្រសើរ កម្មករ និយោជិត មានអារម្មណ៍សប្បាយរីករាយនឹងការងារ។ អ្វីដែលរាជរដ្ឋាភិបាល កំពុងធ្វើ ឆ្លើយតបបានតាមលក្ខខណ្ឌការងារល្អប្រសើរ ពិសេសស្របតាមស្តង់ដាការងារអន្តរជាតិ។<br>-គោលនយោបាយរបស់រាជរដ្ឋាភិបាល ត្រូវបានអនុវត្ត តាមរយៈការលើកកម្ពស់សុខមាលភាពរបស់ប្រជាពលរដ្ឋ ពិសេស ការចូលរួមរបស់វិស័យឯកជនក្នុងការគាំពារសង្គម។<br>-គុណភាពជីវិតរបស់កម្មករនិយោជក ត្រូវបានយកចិត្តទុកដាក់ និងលើកកម្ពស់ដោយរាជរដ្ឋាភិបាល។ |
| ជម្រើសទី២: …….. | -ធ្វើឱ្យមានសេវាសុខភាពមាននៅតាមសហគ្រាសគ្រឹះស្ថាន និងរោងចក្រនិមួយៗសម្រាប់សង្គ្រោះបឋមដល់បញ្ហាសុខភាពរបស់កម្មករនិយោជិត និងនិយោជក។<br>-គ្រោះថ្នាក់ការងារនៅតាមបណ្តាសហគ្រាស គ្រឹះស្ថាន និងរោងចក្រនិមួយៗ ត្រូវបានកាត់បន្ថយតាមរយៈការប្រើប្រាស់សេវាសង្គ្រោះបឋម។<br>-ផលិតភាពរបស់កម្មករនិយោជិត មានលំនឹងថេរ ឬអាចការកើនឡើង បើគ្មានបញ្ហាសុខភាព ឬគ្រោះថ្នាក់ការងារណាមួយកើតឡើងធ្វើឱ្យប៉ះពាល់ ដល់សុខភាពរបស់កម្មករនិយោជិត។ ដូចនេះ និយោជកនឹងទទួលបានប្រាក់ចំណូលកើនឡើង។<br>-ធ្វើឲ្យលក្ខខណ្ឌការងារកាន់តែល្អប្រសើរ  កម្មករនិយោជិត មានអារម្មណ៍ |

| | |
|---|---|
| | សម្បាយរីករាយនឹងការងារ។ អ្វីដែលរាជរដ្ឋាភិបាល កំពុងធ្វើ ឆ្លើយតប បានតាមលក្ខខណ្ឌការងារល្អប្រសើរ ពិសេសស្របតាមស្តង់ដាការងារអន្តរជាតិ។<br>-គោលនយោបាយរបស់រាជរដ្ឋាភិបាល ត្រូវបានអនុវត្តតាមរយៈការលើកកម្ពស់សុខមាលភាពរបស់ប្រជាពលរដ្ឋ ពិសេសការចូលរួមរបស់វិស័យឯកជនក្នុងការគាំពារសង្គម។<br>-គុណភាពជីវិតរបស់កម្មករនិយោជក ត្រូវបានយកចិត្តទុកដាក់ និងលើកកម្ពស់ដោយរាជរដ្ឋាភិបាល។ |

## ២.៥.៣. ទំហំ/វិសាលភាពនៃជម្រើសនីមួយៗ

| ជម្រើស | វិស័យ ឬប្រភេទធុរកិច្ច | ចំនួន ធុរកិច្ច | ឯកសារយោង/ ភស្តុតាង |
|---|---|---|---|
| សំណើបញ្ញត្តិកម្ម: ... | | | |
| ជម្រើសទី១: ......... | ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម សេវាកសិកម្ម ដឹកជញ្ជូន ... (យោងមាត្រា ១ នៃច្បាប់ស្តីពីការងារ) | វិសាលភាពនៃការអនុវត្តក្នុងជម្រើសនេះបានគ្របដណ្តប់លើសហគ្រាស គ្រឹះស្ថាន និងរោងចក្រចំនួនជាង ១៦០០។ | -ច្បាប់ស្តីពីការងារ |
| ជម្រើសទី២: ......... | ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម សេវាកសិកម្ម ដឹកជញ្ជូន ... (យោងមាត្រា ១ នៃច្បាប់ស្តីពីការងារ) | វិសាលភាពនៃការអនុវត្តក្នុងជម្រើសនេះបានគ្របដណ្តប់លើសហគ្រាស គ្រឹះស្ថាន និងរោងចក្រចំនួនជាង ១៦០០។ | -ច្បាប់ស្តីពីការងារ |

## ២.៦. លទ្ធផលនៃកិច្ចពិគ្រោះយោបល់បឋម

ដើម្បីបានដឹងអំពីគុណភាព និងប្រសិទ្ធភាពនៃការអនុវត្តនូវខ្លឹមសារដែលមានក្នុងប្រកាសរួមលេខ ៣៣០ សកបយ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ ២០០០ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស ត្រូវបានរៀបចំឡើងដោយអតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ដោយរួមសហការជាមួយក្រសួងសុខាភិបាល ក្រុមការងារវាយតម្លៃផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរួមសហការជាមួយមន្ត្រីគម្រោងវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តរបស់ទីស្តីការគណៈរដ្ឋមន្ត្រី បានធ្វើការសិក្សាស្រាវជ្រាវរកផលប៉ះពាល់ តាមរយៈការជជែកក្រៅផ្លូវការ មានការប្រជុំពិគ្រោះយោបល់ និងបានចុះទៅស្រាវជ្រាវនៅតាមសហគ្រាស គ្រឹះស្ថាន និងរោងចក្រចំនួន ១២ ក្នុងខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តបន្ទាយមានជ័យ។

លទ្ធផលទទួលបានត្រឡប់មកវិញ តាមរយៈ ការផ្តល់អនុសាសន៍របស់និយោជក តំណាងនិយោជក កម្មករនិយោជិត មន្ត្រីទទួលបន្ទុកខាងផ្នែកពេទ្យការងារ និងមន្ត្រីអធិការកិច្ចមួយចំនួនរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានឯកភាពទទួលយក និងធ្វើអនុសាសន៍មួយចំនួន ដូចខាងក្រោម:

**ក.** គុណភាពខ្លឹមសារ ដែលមានចែងក្នុងប្រកាសរួមនេះ មានលក្ខណៈសមស្រប និងអាចទទួលយកបាន ហើយមានលក្ខណៈស្រដៀងគ្នាជាមួយច្បាប់នៅប្រទេសថៃឡង់ដ៍ ចិន និងជប៉ុនដែរ។ លក្ខខណ្ឌច្បាប់បានតម្រូវឱ្យសហគ្រាស គ្រឹះស្ថាន និងរោងចក្រនីមួយៗត្រូវបង្កើតឲ្យមានបន្ទប់សង្គ្រោះបឋមមួយ ដោយមានភ្ជាប់ជាមួយការបំពាក់ឧបករណ៍សម្ភារៈពេទ្យ ថ្នាំពេទ្យសម្រាប់បម្រើសេវាសង្គ្រោះបឋម ឬសេវាថែទាំសុខភាពដល់កម្មករនិយោជិតរបស់ខ្លួន។

**ខ.** ស្នើសុំឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើការពិនិត្យ និងកែសម្រួលនូវចំណុចមួយចំនួន ដែលមានចែងក្នុងប្រកាសរួមនេះ ឱ្យបានស៊ីគ្នាជាមួយស្ថានភាពបច្ចុប្បន្ន។ ខ្លឹមសារទាំងនោះរួមមាន:

- ឈ្មោះក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យច្បាប់ស្តីពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/កប ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា
- ក្នុងប្រការ ១: គិលានដ្ឋានអចិន្ត្រៃយ៍នេះ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់នាយកដ្ឋានពេទ្យការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- ត្រូវបន្ថែមប្រការមួយចំនួនទៀត ពាក់ព័ន្ធខ្លឹមសារ និងគោលការណ៍ចំណាយសម្រាប់ដំណើរការបន្ទប់សង្គ្រោះបឋម រួមទាំងឧបករណ៍ សម្ភារៈបរិក្ខារពេទ្យដែលមានចែងក្នុងឧបសម្ព័ន្ធ
- ចុងក្រោយ ការចុះហត្ថលេខារបស់តំណាងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

**គ.** ទន្ទឹមនេះ ការកែលម្អនូវខ្លឹមសារមួយចំនួនខាងលើ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវពង្រឹង និងពង្រីកនូវយន្តការការងាររបស់ខ្លួនបន្ថែមទៀត តាមរយៈសកម្មភាពការងារជាយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោម៖

- ពង្រីកការផ្សព្វផ្សាយរបស់ខ្លួនឱ្យបានទូលំទូលាយ តាមរយៈ ការសែតក្នុងស្រុក-ក្រៅស្រុក វិទ្យុ ទូរទស្សន៍ ចុះផ្សព្វផ្សាយអប់រំ និងណែនាំដោយផ្ទាល់។ល។ ធ្វើឲ្យអ្នកប្រតិបត្តិបញ្ញត្តិកម្មនេះ បានជ្រួតជ្រាប និងមានការតាំងចិត្តខ្ពស់ក្នុងការគោរពបញ្ញត្តិកម្មនេះ។ ព្រមទាំងពន្យល់សហគ្រាស គ្រឹះស្ថាន និងរោងចក្រ ឱ្យបានយល់កាន់តែច្បាស់នូវខ្លឹមសារទាំងអស់ដែលមានចែងក្នុងប្រកាសនេះ។ ពិសេស នីតិវិធីនៃការអនុវត្តឱ្យបានត្រឹមត្រូវ ស្របតាមបញ្ញត្តិកម្មនេះ ជៀសវាងការអនុវត្តខុសបន្តទៅទៀត។

- ពង្រឹងយន្តការត្រួតពិនិត្យតាមដាន និងវាយតម្លៃរបស់សមត្ថកិច្ចទទួលខុសត្រូវ ឱ្យបានល្អ និងមិនលំអៀង ស្របតាមបទដ្ឋានគតិយុត្ត។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវធ្វើការត្រួតពិនិត្យតាមដានការអនុវត្តរបស់សហគ្រាស គ្រឹះស្ថាន និងរោងចក្រនីមួយៗ ឱ្យបានទៀងទាត់ ហើយកំណត់ឱ្យបានច្បាស់ អំពីកំហុសឆ្គង តាមរយៈយន្តការដែលមានស្រាប់ ក៏ដូចបង្កើតថ្មី។

- ការដាក់ពិន័យ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បន្តបន្ថែមដល់សហគ្រាស គ្រឹះស្ថានដែលប្រព្រឹត្តផ្ទុយនឹងច្បាប់ស្តីពីការងារដែលបានកំណត់ ព្រោះប្រទេសកម្ពុជា ជាប្រទេសនីតិរដ្ឋ ប្រជាពលរដ្ឋគួរ ប្រកាន់យកច្បាប់ គោរពច្បាប់ជាគោល។ សហគ្រាស គ្រឹះស្ថាន និងរោងចក្រណាមួយ មិនបានអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនត្រូវតែទទួលពិន័យ មិនត្រូវមានការសម្របសម្រួលបន្តទៅទៀតទេ។ យន្តការទាំងនេះ អាចជួយជំរុញដល់យន្តការពង្រឹងការអនុវត្តបញ្ញត្តិកម្មនានាឲ្យកាន់តែមានគុណភាព និងប្រសិទ្ធភាពខ្ពស់។

## ២.៧. ការអនុវត្ត និងការតាមដាន

ដើម្បីឱ្យការអនុវត្តប្រកាសរួមនេះ ឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាពខ្ពស់ ក្រុមការងារវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ យល់ឃើញថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវពង្រឹងយន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃឱ្យបានរឹងមាំ តាំងពីថ្នាក់មូលដ្ឋាន មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រហូតដល់ថ្នាក់ជាតិ មានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។

របៀបរបបធ្វើការអនុវត្តតាមឋានានុក្រមការងារ ស្រុក/ខ័ណ្ឌរាយការណ៍ជូនមន្ទីរ ហើយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវរាយការណ៍ជូនមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យបានទៀងទាត់ ស្របតាមពេលដែលបានកំណត់ ហើយជារៀងរាល់ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំនីមួយៗ ត្រូវមានប្រជុំបូកសរុបរបាយការណ៍ និងលើកទិសដៅការងារអនុវត្តបន្តទៀត។

ទន្ទឹមនឹងនេះ ក្រុមការងារវាយតម្លៃផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកំណត់នូវផែនការនៃការចុះត្រួតពិនិត្យតាមដាន និងវាយតម្លៃឱ្យបានទៀងទាត់ រៀងរាល់មួយឆ្នាំម្តង នៅក្នុងអំឡុងខែមិថុនា ដោយប្រើប្រាស់យន្តការ ដែលមានស្រាប់ គឺក្រុមអធិការកិច្ចតែមួយ ឬបន្ថែមយន្តការថ្មី បើមានករណីចាំបាច់។

## ២.៨. សេចក្តីសន្និដ្ឋាន

តាមរយៈ ការប្រតិបត្តិលើប្រកាសរួមលេខ ៣៣០ សកបយ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស ដែលមានអាយុកាលជាង១៨ឆ្នាំនេះ បានបង្ហាញឱ្យឃើញថា សិទ្ធិទទួលបានការថែទាំសុខភាពរបស់កម្មករនិយោជិត ត្រូវបានលើកកម្ពស់ពីសំណាក់និយោជក ក៏ដូចរាជរដ្ឋាភិបាលកម្ពុជា។ ឈរលើស្មារតីនេះ ដើម្បីឱ្យការអនុវត្តប្រកាសរួមនេះខាងលើ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ជាងមុន ក្រុមការងារវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសិក្សា និងវិភាគរកឃើញនូវជម្រើសពីរ គឺ (១). ប្រកាសរួមស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស និង (២).ការបង្កើតគិលានដ្ឋានភាពជាដៃគូរបស់រដ្ឋ និងម្ចាស់សហគ្រាសគ្រឹះស្ថាន និងរោងចក្រ។

ក្នុងជម្រើសទាំងពីរខាងលើ ក្រុមការងារបានពិនិត្យឃើញថា ជម្រើសទីមួយ មានលក្ខណៈសម្បត្តិសមស្រប គ្រប់ជ្រុងជ្រោយទាំងខ្លឹមសារ និងនីតិវិធីណែនាំក្នុងការអនុវត្ត។ល។ ពិសេសផលចំណេញ ឬផលប្រយោជន៍ដែលទទួលបានពីការយកជម្រើសទីមួយមកអនុវត្ត រួមមាន៖

- ប្រកាសរួមនេះ បានអនុវត្តជាង ១៨ឆ្នាំ និយោជក និងអ្នកពាក់ព័ន្ធភាគច្រើនបានយល់ច្បាស់ពីខ្លឹមសារនិងនីតិនៃការអនុវត្ត ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈគ្រាន់តែពង្រឹងការងារគ្រប់គ្រង អប់រំផ្សព្វផ្សាយ និងតាមដានបន្ថែមទៀតប៉ុណ្ណោះ។

- ខ្លឹមសារ និងនីតិវិធី ដែលមានចែងក្នុងប្រកាសរួមនេះ មានលក្ខណៈសមស្របតាមស្តង់ដាអន្តរជាតិ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រាន់តែពិនិត្យ និងកែសម្រួលខ្លឹមសារខ្វះខាតមួយចំនួន ឲ្យបានសមស្របតាមស្ថានភាពបច្ចុប្បន្នទាំងផ្នែកសេដ្ឋកិច្ច និងសង្គម។

- រាល់ការចំណាយសម្រាប់ការតាក់តែង កែសម្រួល និងប្រតិបត្តិនៃប្រកាសរួមនេះ មានចំនួនតិចជាងលើការចំណាយក្នុងជម្រើសទីពីរ ដោយនិយោជកគ្រាន់តែចំណាយសម្រាប់ប្រាក់ខែគិលានុបដ្ឋាក-យិកា គ្រូពេទ្យ មូលដ្ឋានឧបករណ៍សម្ភារៈពេទ្យ ថ្នាំពេទ្យ និងដំណើរការបន្ទប់សង្គ្រោះបឋម។ល។

ជាសរុប ភាគីនិយោជក ដែលជាម្ចាស់រោងចក្រមួយ ត្រូវចំណាយអស់ចំនួន US$ ៣១.៧៥៩ ចាប់តាំងពីដំណើរការតាក់តែងប្រកាសនេះ រហូតដល់អនុវត្តបានមួយឆ្នាំ។ ចំណែកភាគីរាជរដ្ឋាភិបាល ដែលមានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាអ្នកភ្នាក់ងារប្រតិបត្តិផ្ទាល់ មានភារកិច្ច និងទទួលខុសត្រូវរួម ក្នុងការតាក់តែងរៀបចំប្រកាសរួមនេះ ការបោះពុម្ពអាជ្ញាប័ណ្ណ និងចំណាយលើការចុះត្រួតពិនិត្យតាមដាន និងវាយតម្លៃ។ល។ សរុបការចមណាយអស់មានចំនួន US$ ១៨០.០៣៨តែប៉ុណ្ណោះ។

ដោយឡែក លទ្ធផលនៃការចុះជួបសម្ភាសន៍ជាមួយតំណាងនិយោជកនានា ដែលក្រុមការងារវាយតម្លៃផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានជួបសម្ភាសន៍ទាំង ១២ រោងចក្រនោះ ក៏ដូចការលើកឡើងរបស់បុគ្គលិកមន្ត្រីរាជការ ដែលទទួលបន្ទុកបានឆ្លើយថា ប្រកាសរួមនេះ មានខ្លឹមសារ និងនីតិវិធីនៃការអនុវត្តមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមិនមានសំណូមពរទៀតទេ៕

# ក្រុមការងារ និងអ្នកពាក់ព័ន្ធ

| ដំណើរការ | ឈ្មោះ | មុខងារ | ទំនាក់ទំនង | ហត្ថលេខា | កាលបរិច្ឆេទ |
|---|---|---|---|---|---|
| រៀបចំដោយ (កបវ- MLVT) | ឯ.ឧ ហេង សួរ | ប្រធាន RIA/MLVT | Tel: 012693777<br>hengsour@yahoo.com | | |
| ត្រួតពិនិត្យដោយ (ORIA) | លោកសំ សំណាង | សមាជិក RIA | Tel: 077644095<br>somnangs001@gmail.com | | |
| | ឯ.ឧ អេង រត្នមុនី | ប្រធានផ្នែក RIA | Tel: 012912009<br>eratmoni@gmail.com | | |
| | ឯ.ឧ ម៉ម សារិទ្ធ | ប្រធានផ្នែក CBA | Tel: 016389709<br>mamsarith@yahoo.com | | |
| ឯកភាពដោយ (ORIA) | ឯ.ឧ ប៉ិច សុខា | អ្នកគ្រប់គ្រងគម្រោង | Tel: 012698999<br>pechsokha566@gmail.com | | |
| បញ្ចូលទិន្នន័យដោយ (កបវ-MLVT) | លោក តឹប អឿន | អនុប្រធានក្រុម RIA/MLVT | Tel: 012606572<br>tepoeuntvet@gmail.com | | |
| | លោក ទី សេរីរិទ្ធ | សមាជិកក្រុម RIA/MLVT | Tel: 012851884<br>sereirith_ty@yahoo.com | | |
| | ក. អ៊ូច ជា ច័ន្ទមល្លិកា | សមាជិកក្រុម RIA/MLVT | Tel: 089290838<br>cheachan_molika@hotmail.com | | |
| បញ្ចូលក្នុងគេហទំព័រដោយ | | | | | |

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ៣៣០ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០០០

# ប្រកាសរួម

## ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងក្រសួងសុខាភិបាល

## ស្តីពី

## ការរៀបចំគិលានដ្ឋានសហគ្រាស

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ/បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល

## សំរេច

**ប្រការ១.-** និយោជកនៃសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ហើយដែលមានកម្មករនិយោជិតចាប់ពី ៥០ នាក់ឡើងទៅ ត្រូវរៀបចំឱ្យមានគិលានដ្ឋានអចិន្ត្រៃយ៍មួយនៅក្នុងសហគ្រាសរបស់ខ្លួន ។

គិលានដ្ឋានអចិន្ត្រៃយ៍នេះ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់នាយកដ្ឋានពេទ្យការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

គិលានដ្ឋានអចិន្ត្រៃយ៍នេះ ត្រូវបានកំណត់តាមលក្ខខណ្ឌនៃទីតាំង និងទំហំ ចំនួន និងគុណភាពបុគ្គលិកសុខាភិបាល ហើយនិងសំភារៈ បរិក្ខារពេទ្យ ព្រមទាំងឱសថ ។

**ប្រការ២.-** អំពីទីតាំង និងទំហំ

គិលានដ្ឋានត្រូវស្ថិតនៅជិតកន្លែងធ្វើការ មានភាពងាយស្រួលដល់អ្នកជំងឺចេញ-ចូល មានពន្លឺគ្រប់គ្រាន់ មានខ្យល់អាកាសល្អ នៅឆ្ងាយពីសម្លេងលាន់ឮខ្លាំង ឆ្ងាយពីទីតាំងដាក់កាកសំណល់ គ្មានធូលី គ្មានផ្សែង គ្មានក្លិន និងត្រូវមានទំហំសមស្របទៅតាមចំនួនកម្មករនិយោជិត ប៉ុន្តែយ៉ាងតូចបំផុតឱ្យមានផ្ទៃ ២០ ម៉ែត្រក្រឡា ។

**ប្រការ៣.-** អំពីចំនួន និងគុណភាពបុគ្គលិកសុខាភិបាល

ចំនួន និងគុណភាពនៃបុគ្គលិកសុខាភិបាល ត្រូវបានកំណត់ស្របតាមចំនួនកម្មករនិយោជិតនៃសហគ្រាស គ្រឹះស្ថាន ដូចមានក្នុងតារាងខាងក្រោមនេះ :-

| ចំនួនកម្មករនិយោជិតក្នុងសហគ្រាស | ចំនួនគិលានុបដ្ឋាកឬគិលានុបដ្ឋាយិកា | ចំនួនគ្រូពេទ្យ | វត្តមានអប្បបរមារបស់គ្រូពេទ្យសំរាប់មួយថ្ងៃ៨ ម៉ោង |
|---|---|---|---|
| ៥០ - ៣០០ នាក់ | ១ នាក់ ប្រចាំការ | វេជ្ជបណ្ឌិត១ នាក់ ឬគ្រូពេទ្យមធ្យម១ នាក់ | ២ ម៉ោង |
| ៣០១ - ៦០០ នាក់ | ១ នាក់ ប្រចាំការ | វេជ្ជបណ្ឌិត១ នាក់ | ២ ម៉ោង |
| ៦០១ - ៩០០ នាក់ | ២ នាក់ ប្រចាំការ | វេជ្ជបណ្ឌិត១ នាក់ | ៣ ម៉ោង |
| ៩០១ - ១៤០០ នាក់ | ២ នាក់ ប្រចាំការ | វេជ្ជបណ្ឌិត១ នាក់ | ៤ ម៉ោង |
| ១៤០១ - ២០០០ នាក់ | ២ នាក់ ប្រចាំការ | វេជ្ជបណ្ឌិត១ នាក់ | ៦ ម៉ោង |
| លើសពី ២០០០ នាក់ | ៣ នាក់ ប្រចាំការ | វេជ្ជបណ្ឌិត១ នាក់ | ៨ ម៉ោង |

កាលណាសហគ្រាស គ្រឹះស្ថាន មានធ្វើការបន្ថែមម៉ោង បុគ្គលិកនៃគិលានដ្ឋាន ត្រូវមានគិលានុបដ្ឋាក-យិកា និងគ្រូពេទ្យប្រចាំការក្នុងរយៈពេលធ្វើការបន្ថែមម៉ោងនេះ ។

**ប្រការ៤.-** អំពីសំភារៈ បរិក្ខារ និងឱសថ

សំភារៈជាគ្រឿងសង្ហារឹមត្រូវមានជាអប្បបរមាគឺ :-

- តុធ្វើការមួយ
- កៅអីអង្គុយមានបង្អែកបី

-ទូសំរាប់ទុកដាក់ឯកសារមួយ

- ទូសំរាប់ដាក់តាំងឱសថមួយ

- គ្រែពីរមានពូក និងកម្រាល

- បរិធានសំរាប់រំងាប់មេរោគមួយ (STERILISATEUR)

បរិក្ខារពេទ្យ និងឱសថ ត្រូវមានជាចាំបាច់ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ៥.-** ចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតលើសពី ២០០នាក់ ត្រូវរៀបចំឱ្យមានគ្រែសំរាប់អោយអ្នករបួស និងអ្នកជំងឺសំរាក នៅជិតគិលានដ្ឋានទៅតាមអត្រាពីរភាគរយនៃចំនួនកម្មករនិយោជិតក្នុងសហគ្រាស គ្រឹះស្ថានរហូតដល់ចំនួន ២០គ្រែ ជាអតិបរមា ។

**ប្រការ៦.-** កាលណាសហគ្រាស គ្រឹះស្ថាន មានសាខា ឬការដ្ឋានមួយ ឬច្រើនដែលមានកម្មករនិយោជិតចាប់ពី ៥០នាក់ឡើងទៅ ហើយដែលស្ថិតនៅចំងាយលើសពី ប្រាំគីឡូម៉ែត្រពីការដ្ឋានធំ និយោជកត្រូវតែផ្តល់ចំពោះសាខា ឬការដ្ឋានទាំងនោះ ឱ្យដូចជាចំពោះការដ្ឋានធំដែរ នូវមធ្យោបាយសង្គ្រោះ និងព្យាបាលកម្មករនិយោជិតខ្លួនឱ្យបានសព្វគ្រប់ដូចជា បុគ្គលិកពេទ្យ សំណង់ សំភារៈ វត្ថុរុំរបួស និងឱសថព្យាបាល ។

**ប្រការ៧.-** ចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតមិនដល់ ៥០នាក់ ត្រូវមានមធ្យោបាយសង្គ្រោះដូចខាងក្រោមនេះ :-

- កម្មករនិយោជិតក្រោម២០នាក់ ត្រូវមានប្រអប់សង្គ្រោះមួយ និងអ្នកជំនួយសង្គ្រោះម្នាក់ ។
- កម្មករនិយោជិតពី២០ នាក់ដល់ ៤៩នាក់ ត្រូវមានបន្ទប់រុំរបួសមួយ និងគិលានុប្បដ្ឋាក ឬគិលានុប្បដ្ឋាយិកាម្នាក់ ។

គ្រឿងសង្ហារឹម បរិក្ខារពេទ្យ និងឱសថ ដែលមានជាចាំបាច់ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ៨.-** អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៩.-** ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **ក្រសួងសុខាភិបាល** | **ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា** |
| **ហត្ថលេខា និង ត្រា** | **ហត្ថលេខា និង ត្រា** |
| វេជ្ជ. ហុង សុនហួរ | អ៊ិត សំហេង |

តារាងឧបសម្ព័ន្ធ នៃប្រកាសរួមលេខ ៣៣០ សកបយ.

ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០០០

១.ប្រអប់សង្គ្រោះ :

| | | | |
|---|---|---|---|
| -កន្ត្រៃអ៊ីណុក ១ | -បង់ស្អិតរមូរ ១ | -កំប្រេស ១០ | -Alcool Iodé 200ml |
| -ដង្កៀបអ៊ីណុក ២ | -បង់ស្បៃរមូរ ៥ | -សំឡីជក់ទឹក ១០០ក្រ. | - Eau Oxygéné200ml |
| -ស្រោមដៃ ២០ | -បង់យឺតរមូរ ៥ | -ប្រេងខ្យល់ ១ដប | -Ether 50ml |
| -សាប៊ូដុំ ១ | -ក្រណាត់សបីជ្រុង៤ | -ប្រេងកូឡា ១ ដប | -Analgésiques |
| | | | - Anti-diarrhéiques |

២.បន្ទប់វិរបួស :

| គ្រឿងសង្ហារឹម | បរិក្ខារពេទ្យ | ឱសថ |
|---|---|---|
| -គ្រែមានពូក និងកំរាល ១ | -Trousse pour petite chirurgie | -Antihémorragique |
| -តុធ្វើការ ១ | -Tensiomètre + stétoscope | -Analgésiques |
| -កៅអីអង្គុយមានបង្អែក ៣ | -Eau Oxygénée-Alcool Iodé | -Antispasmodiques |
| -ទូរដាក់សំភារៈបរិក្ខារ និងឱសថមួយ | -Ether | -Anti-infectieuses |

៣.គិលានដ្ឋាន :

បរិក្ខារពេទ្យ

-Trousse pour petite chirurgie
-Tensiomètre + Stétoscope bi-auriculaire
-Chronomètre à secondes
-Marteau à réflexes
-Abaisse-langue
-Otoscope
-Spéculum nasal
-Thermomètre médical
-Thermomètre d'ambiance
-Vaccinostyles
-Nécessaires pour petits pansements
-Seringues en plastiques (divers numéros )
-Gants

ឱសថ :

1- Les Anti-infecteuses :
   A. Anti-bactériennes
   B. Antifugiques
   C. Antihelminthiques
2- Les Analgésiques
3- Les Anti-inflammatoires non stéroïdes (AINS)
4- Les Anesthésiques locaux
5- Les Antihistaminiques
6- Les Corticoïdes
7- Les Anti-asthmatiques
8- Les Antitussifs
9- Les Anti-migraineux
10- Les Anti-diarrhéiques
11- Les Diurétiques
12- Les Vitamines
13- Les Sels minéraux
14- Les Médicaments utilisés en cardio-angiologie :
   A. Tonicardiaque
   B. Anti-hypertenseur
15- Les Médicaments utilisés en gastro-entérologie
16- Les Anti-anémiques
17- Les Antihémorragiques
18- Les Antiseptiques externes, Cicatrisants percutanés
19- Les Coollyres
20- Les Sérums

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ក្រុមអនុវត្តគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត**

**សូមគោរពជូន**

**ឯកឧត្តម យឹម ណុលសន**

**នាយកគម្រោងវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត**

**កម្មវត្ថុ:** សំណើសុំថវិកាសម្រាប់ចុះពិគ្រោះយោបល់ជាមួយសហគ្រាសនៅតាមខេត្តចំនួន ៣។

**យោង:** តាមការចាំបាច់របស់ក្រុមអនុវត្តគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមនាយក** មេត្តាជ្រាបថា ក្រុមអនុវត្តគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានគម្រោងចុះទៅពិគ្រោះយោបល់ជាមួយសហគ្រាសនៅខេត្តកោះកុង ព្រះសីហនុ ចាប់ពីថ្ងៃទី២០ រហូតដល់ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៤ និងបន្តទៅខេត្តបន្ទាយមានជ័យពីថ្ងៃទី២៧ រហូតដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤។ ការចុះពិគ្រោះយោបល់នេះ មានគោលបំណងដើម្បីប្រមូលនូវព័ត៌មាន និងទទួលយកនូវមតិយោបល់នានា ធ្វើជាមូលដ្ឋានក្នុងការវិភាគនិងធ្វើការវាយតម្លៃផលប៉ះពាល់លើប្រកាសស្តីពី "ការរៀបចំគិលានដ្ឋានសហគ្រាស" ឲ្យទទួលបាននូវគុណភាព និងប្រសិទ្ធភាពក្នុងការអនុវត្ត។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមនាយក** មេត្តាជ្រាប និងជួយសម្រួលផ្នែកថវិកាដល់ក្រុមការងារវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងដំណើរការចុះពិគ្រោះយោបល់នេះដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមនាយកគម្រោង** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០១៤

**ជ.ប្រធានក្រុមអនុវត្តគម្រោង** RIA

**អនុប្រធាន**

**គីម រឿន**

ចម្លងជូន:

- រង្គភាពគ្រប់គ្រងគម្រោង RIA
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋាន អបវ អគ្គនាយកដ្ឋានការងារ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និង NEA
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**ក្រុមអនុវត្តគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត**

## សំនួរពិភាក្សា

កម្រងសំនួរទាំងអស់នេះ មានគោលបំណងដើម្បីប្រមូលនូវព័ត៌មាន និងទទួលយកនូវមតិ និង យោបល់នានា ដើម្បីជាមូលដ្ឋានក្នុងការវិភាគ និងការវាយតម្លៃផលប៉ះពាល់លើប្រកាសស្តីពីការរៀបចំគិលានដ្ឋានសហគ្រាសដើម្បីទទួលបាននូវគុណភាព និងប្រសិទ្ធភាព។ *(ចម្លើយរបស់លោកអ្នកនឹងត្រូវបានប្រើប្រាស់ក្នុងគោលដៅសិក្សាស្រាវជ្រាវប៉ុណ្ណោះ)*

១ ឈ្មោះសហគ្រាស:

- អស័យដ្ឋាន :.................................................................................................................................
  .................................................................................................................................

២ អ្នកផ្តល់ព័ត៌មាន :

- ឈ្មោះ.........................................................................ភេទ...........តួនាទី...................................................
  .......................................................................................................................លេខទូរស័ព្ទ..................................

៣ តើសហគ្រាសចាប់ផ្តើមដំណើរការពីឆ្នាំណា? ស្ថិតនៅក្នុងវិស័យអ្វី?

- ឆ្នាំ........................វិស័យ.................................................................................................................................

៤ តើសហគ្រាសមានចំនួនបុគ្គលិកប៉ុន្មាន?

- □ ៥០រហូតដល់៣០០
- □ ៣០១រហូតដល់៦០០
- □ ៦០១ រហូតដល់ ៩០០
- □ ៩០១ រហូតដល់១៤០០
- □ ១៤០០ រហូតដល់ ២០០០
- □ លើសពី ២០០០

៥ តើសហគ្រាសមានករណីដូចខាងក្រោម ឬទេ?សូមជ្រើសរើស ចម្លើយ ៖

- បុគ្គលិកមានគ្រោះថ្នាក់ក្នុងអំឡុងពេលធ្វើការជាមធ្យមក្នុង១ឆ្នាំ..........................នាក់(ស្ត្រី.........................)
  - □ ដួលសន្លប់ជាមធ្យមក្នុង១ឆ្នាំ.................................នាក់(ស្ត្រី............................)
  - □ របួសជាមធ្យមក្នុង១ឆ្នាំ...................................នាក់(ស្ត្រី............................)
  - □ ផ្សេងៗជាមធ្យមក្នុង១ឆ្នាំ........................................នាក់(ស្ត្រី..................................)

៦ តើសហគ្រាសបាន រៀបចំគិលានដ្ឋានដែរឬទេ?

- មាន មូលហេតុ :
  - □ ប្រកាសរួមលេខ ៣៣០ សកបយ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស
  - □ ស្តង់ដារបស់សហគ្រាស

□ ផ្សេងៗ(សូមបញ្ជាក់)

- មិនមាន មូលហេតុ :
  - □ ថវិកា
  - □ មិនចាំបាច់
  - □ ផ្សេងៗ(សូមបញ្ជាក់)

៦ តើលោកអ្នកយល់ឃើញថា ការរៀបចំមានគិលានដ្ឋានក្នុងសហគ្រាស មានអត្ថប្រយោជន៍ដែរឬទេ?

- មាន មូលហេតុ
  ..................................................................................................................
  ..................................................................................................................
  ..................................................................................................................
- មិនមាន មូលហេតុ
  ..................................................................................................................
  ..................................................................................................................

៧ តើអ្នកយល់យ៉ាងណាលើខ្លឹមសារប្រកាសរួមលេខ ៣៣០ សកបយ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស (ទាក់ទងនឹងបញ្ហាខាងក្រោម)?

- និយោជិតចាប់ពី៥០នាក់ឡើងទៅចាំបាច់មានគិលានដ្ឋានសហគ្រាស
  ..................................................................................................................
  ..................................................................................................................
- ទំហំនិងទីតាំង
  ..................................................................................................................
  ..................................................................................................................
- ចំនួន និងគុណភាពបុគ្គលិកសុខាភិបាល
  ..................................................................................................................
  ..................................................................................................................
- សំភារៈ បរិក្ខារ និងឪសថ
  ..................................................................................................................
  ..................................................................................................................
- ផ្សេងៗ
  ..................................................................................................................
  ..................................................................................................................

៨ យោបល់ផ្សេងៗ?

..................................................................................................................

..................................................................................................................

## កម្មវិធីសម្រាប់ពិគ្រោះយោបល់ជាមួយសហគ្រាសតាមបណ្តាខេត្តលើការ
## វាយតម្លៃបឋមនៃប្រកាសស្តីពី "ការរៀបចំគិលានដ្ឋានសហគ្រាស"
## (ខេត្ត ព្រះសីហនុ និង កោះកុង)

| ថ្ងៃ | ពេលវេលា | សកម្មភាព |
|---|---|---|
| ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៤ | | ចេញដំណើរពីរាជធានីភ្នំពេញទៅខេត្តព្រះសីហនុ |
| ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៤ | | |
| | ៨:០០ - ១២:០០ | ពិគ្រោះយោបល់ជាមួយសហគ្រាស លីឌើ អ៊ិនដាសស្ទ្រី ខូអិលធីឌី |
| | ១២:០០ - ១៤:០០ | សំរាកពិសារបាយថ្ងៃត្រង់ |
| | ១៤:០០ - ១៧:០០ | ពិគ្រោះយោបល់ជាមួយសហគ្រាស ស្រាបៀរកម្ពុជា ខេមប្រ៊ូ |
| ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ | | |
| | ៨:០០ - ១២:០០ | ពិគ្រោះយោបល់ជាមួយសហគ្រាស ខេមបូឌាន ហ្សេតវេ អាន់ឌើវែរ |
| | ១២:០០ - ១៤:០០ | សំរាកពិសារបាយថ្ងៃត្រង់ |
| | ១៤:០០ - ១៧:០០ | ពិគ្រោះយោបល់ជាមួយសហគ្រាស យ្លៀរផ្ញើ លេឌើ សីបផ្លាយ |
| ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៤ | | ចេញដំណើរពីខេត្តព្រះសីហនុទៅខេត្តកោះកុង |
| ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤ | | |
| | ៨:០០ - ១២:០០ | ពិគ្រោះយោបល់ជាមួយសហគ្រាស ខេ ខេ អ៊ិន |
| | ១២:០០ - ១៤:០០ | សំរាកពិសារបាយថ្ងៃត្រង់ |
| | ១៤:០០ - ១៧:០០ | ពិគ្រោះយោបល់ជាមួយសហគ្រាស ស៊ូហ្គើរ អ៊ិនដាសស្ទ្រី ខមភេនី លិមិធិត |
| ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤ | | |
| | ៨:០០ - ១២:០០ | ពិគ្រោះយោបល់ជាមួយសហគ្រាស យ៉ា ហ្សាគិ ខេមបូឌា |
| | ១២:០០ - ១៤:០០ | សំរាកពិសារបាយថ្ងៃត្រង់ |
| | ១៤:០០ - ១៧:០០ | ពិគ្រោះយោបល់ជាមួយសហគ្រាស មីកាសា ស្ព័ត |
| ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៤ | | ចេញដំណើរពីខេត្តកោះកុងមករាជធានីភ្នំពេញ |

### កម្មវិធីសម្រាប់ពិគ្រោះយោបល់ជាមួយសហគ្រាសតាមបណ្តាខេត្តលើការ
### វាយតម្លៃបឋមនៃប្រកាសស្តីពី "ការរៀបចំគិលានដ្ឋានសហគ្រាស"
### (ខេត្ត បន្ទាយមានជ័យ)

| ថ្ងៃ | ពេលវេលា | សកម្មភាព |
|---|---|---|
| ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១៤ | | ចេញដំណើរពីរាជធានីភ្នំពេញទៅខេត្តបន្ទាយមានជ័យ |
| ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១៤ | | |
| | ៨:០០ - ១២:០០ | ពិគ្រោះយោបល់ជាមួយសហគ្រាស TK Garmend Sisophon |
| | ១២:០០ - ១៤:០០ | សំរាកពិសារបាយថ្ងៃត្រង់ |
| | ១៤:០០ - ១៧:០០ | ពិគ្រោះយោបល់ជាមួយសហគ្រាស SP Brother Sisophon |
| ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ | | |
| | ៨:០០ - ១២:០០ | ពិគ្រោះយោបល់ជាមួយសហគ្រាស Campack Company Co,.LTD |
| | ១២:០០ - ១៤:០០ | សំរាកពិសារបាយថ្ងៃត្រង់ |
| | ១៤:០០ - ១៧:០០ | ពិគ្រោះយោបល់ជាមួយសហគ្រាស SC WADO Component (Cambodai) Co,.LTD |
| ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ | | |
| | ៨:០០ - ១២:០០ | ពិគ្រោះយោបល់ជាមួយសហគ្រាស Hi-Tech (Cambodai) Co,.LTD |
| | ១២:០០ - ១៤:០០ | សំរាកពិសារបាយថ្ងៃត្រង់ |
| ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤ | | ចេញដំណើរពីខេត្តបន្ទាយមានជ័យទៅរាជធានីភ្នំពេញ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
ក្រុមអនុវត្តគម្រោងវាយតម្លៃលើផលប៉ះពាល់
នៃលិខិតបទដ្ឋានគតិយុត្ត

## របាយការណ៍ស្តីពីការចុះពិគ្រោះយោបល់ជាមួយសហគ្រាសលើការវាយតម្លៃបឋមនៃប្រកាសស្តីពី "ការរៀបចំគិលានដ្ឋានសហគ្រាស" នៅខេត្តព្រះសីហនុ ខេត្តកោះកុង និងខេត្តបន្ទាយមានជ័យ ចាប់ពីថ្ងៃទី២០ ដល់ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤

ឆ្នាំពីពាន់ដប់បួន ខែសីហា ចាប់ពីថ្ងៃទីម្ភៃ ដល់ ថ្ងៃទីសាមសិបមួយ ក្រុមការងារអនុវត្តគម្រោង RIA របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី និងក្រុមការងារអនុវត្តគម្រោង RIA របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះពិគ្រោះយោបល់ជាមួយសហគ្រាសលើការវាយតម្លៃបឋមនៃប្រកាសស្តីពី "ការរៀបចំគិលានដ្ឋានសហគ្រាស" នៅខេត្តព្រះសីហនុ ខេត្តកោះកុង និងខេត្តបន្ទាយមានជ័យ ដើម្បីប្រមូលនូវព័ត៌មាន និងទទួលយកនូវមតិ និងយោបល់នានាដើម្បីជាមូលដ្ឋានក្នុងការវិភាគ ឲ្យទទួលបាននូវគុណភាព និងប្រសិទ្ធភាព (សូមភ្ជាប់មកជាមួយនូវបញ្ជីវត្តមាន)។

### ថ្ងៃទី២១ ដល់ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤

ក្រុមការងារបានចុះទៅកាន់ទីតាំងជាក់ស្តែងក្រុមហ៊ុនទាំងបួន របស់ក្រុងព្រះសីហនុ និងទទួលបានលទ្ធផលដូចខាងក្រោម

| | ឈ្មោះក្រុមហ៊ុន | | | |
|---|---|---|---|---|
| | លីឌើអ៊ិនដាស្ទ្រី ខូអិលធីឌី | ខេមប្រ៊ូ (CAMBREW LTD) | ខេមបូខាន ហ្វេតទេ អាន់ឌើវែរ | ឃ្សឿងធ្វើ លេឌើ សីបន្លាយ |
| អាសយដ្ឋាន | សហគ្រាសនេះ ស្ថិតនៅក្រុមទី៨សង្កាត់ទី១ ក្រុងព្រះសីហនុ ខេត្ត ព្រះសីហនុ។ | សហគ្រាសនេះ ស្ថិតនៅក្រុមទី៨សង្កាត់ទី១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ | សហគ្រាសនេះ ស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេស ខេត្តព្រះសីហនុ។ | ក្រុមហ៊ុននេះ ស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេស ខេត្តព្រះសីហនុ។ |
| ចាប់ផ្តើមដំណើរការ និងវិស័យ | សហគ្រាសចាប់បើកនូវឆ្នាំ២០០៦ក្នុងវិស័យកាត់ដេរ។ | សហគ្រាសចាប់បើកនូវឆ្នាំ១៩៩១ក្នុងវិស័យឧស្សាហកម្ម(ផលិតស្រាបៀរ អង្គរ)។ | សហគ្រាសចាប់បើកនូវឆ្នាំ២០០០ ក្នុងវិស័យកាត់ដេរ ។ | សហគ្រាសចាប់បើកនូវឆ្នាំ២០១២ ក្នុងវិស័យឧស្សាហកម្ម។ |
| ចំនួនបុគ្គលិកសរុប និងចំនួនបុគ្គលិក មានគ្រោះថ្នាក់ក្នុងអំឡុងពេលធ្វើការជាមធ្យមក្នុង១ឆ្នាំ | សហគ្រាសមានបុគ្គលិកចំនួនប្រមាណ ១៥០០រហូតដល់ ២០០០នាក់ និងមានបុគ្គលិកមានគ្រោះថ្នាក់ក្នុងអំឡុងពេលធ្វើការជាមធ្យមក្នុង១ឆ្នាំ២០ | សហគ្រាសមានបុគ្គលិកចំនួនប្រមាណ ៥០១រហូតដល់១៥០០ នាក់។ សហគ្រាសនេះមានបុគ្គលិកមានគ្រោះថ្នាក់ក្នុងអំឡុងពេលធ្វើការជាមធ្យមក្នុង១ឆ្នាំ | សហគ្រាសមានបុគ្គលិកចំនួនប្រមាណ ៣០១ រហូតដល់ ៦០០ នាក់។ សហគ្រាសនេះមានបុគ្គលិកមានគ្រោះថ្នាក់ក្នុងអំឡុងពេលធ្វើការជាមធ្យមក្នុង១ឆ្នាំ៨ | សហគ្រាសមានបុគ្គលិកចំនួនប្រមាណ៦០១ រហូតដល់៥០០នាក់ ។សហគ្រាសនេះមានបុគ្គលិកមានគ្រោះថ្នាក់ក្នុងអំឡុង |

| | | | | |
|---|---|---|---|---|
| | នាក់ ស្ត្រី១៨នាក់។ | ២០នាក់។ | ទៅ៩នាក់។ | ពេលធ្វើការជាមធ្យមក្នុង១ឆ្នាំ៥០នាក់។ |
| **គិលានដ្ឋានរបស់សហគ្រាស** | សហគ្រាសមានរៀបចំគិលានដ្ឋានដែលគោរពទៅតាមប្រកាសលេខ ៣៣០/សកបយ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាសនិងភាពចាំបាច់របស់សហគ្រាស។ | សហគ្រាសមានរៀបចំគិលានដ្ឋានដែលគោរពទៅតាមប្រកាសលេខ៣៣០សកបយ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស។ | សហគ្រាសមានរៀបចំគិលានដ្ឋានដែលគោរពទៅតាមប្រកាសលេខ៣៣០សកបយ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស។តាមរយៈការចុះពិគ្រោះយោបល់ជាក់ស្តែងគិលានដ្ឋានរបស់សហគ្រាសនេះមានលក្ខណៈល្អប្រសើរ និងមានពេទ្យប្រចាំការចំនួនមួយនាក់ និងវេជ្ជបណ្ឌិតមួយនាក់។ | សហគ្រាសមានរៀបចំគិលានដ្ឋានដែលគោរពទៅតាមប្រកាសលេខ៣៣០សកបយ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស។តាមរយៈការចុះពិគ្រោះយោបល់ជាក់ស្តែងគិលានដ្ឋានសហគ្រាសនេះនូវពុំទាន់មានលក្ខណៈល្អប្រសើរនូវឡើយទេ និងមានពេទ្យប្រចាំការតែមួយនាក់ និងពុំមានវេជ្ជបណ្ឌិតទេ។ |
| **មតិ និង យោបល់ស្តីពីប្រកាស** | | តាមរយៈអនុសាសន៍របស់សហគ្រាស ការរៀបចំគិលានដ្ឋាននេះផ្តល់ផល ចំនេញដល់និយោជកផង និង បុគ្គ-លិកផង។ សហគ្រាសយល់ថាប្រកាសនេះមានលក្ខណៈសមរម្យហើយ។ | ទន្ទឹមនោះ ខាងសហ-គ្រាសក៏មានជាមតិផងដែរទៅលើប្រកាសគឺប្រកាសនេះមានលក្ខណៈលម្អិតពីកាតព្វកិច្ចរបស់ក្រុមហ៊ុននិងមានរៀបរាប់ផងដែរនូវសម្ភារៈនិងឧបករណ៍សម្រាប់គិលាដ្ឋាន។ | ប៉ុន្តែសហគ្រាសយល់ឃើញថាចំនួនបុគ្គលិក ៥០ នាក់ គឺមានចំនួនតិចពេកក្នុងការរៀបចំ គិលានដ្ឋាន |
| **ផ្សេងៗ** | | | គិលាដ្ឋាននូវមានទំហំតូចចង្អៀត។ | គិលាដ្ឋាននូវមានទំហំធំ ប៉ុន្តែមិនទាន់មានវេជ្ជបណ្ឌិត។ |

**ថ្ងៃទី២៤ ដល់ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤**

ក្រុមការងារបានចុះទៅកាន់ទីតាំងជាក់ស្តែងក្រុមហ៊ុនទាំងបួន របស់ខេត្តកោះកុង និងទទួលបានលទ្ធផលដូចខាងក្រោម

| | **ឈ្មោះក្រុមហ៊ុន** | | | |
|---|---|---|---|---|
| | **ខេ ខេ អ៊ិន** | **ស៊ូហ្វើរ អ៊ិនដាសស្ទ្រី ខមភេនី លីមីធីត** | **យ៉ា ហ្សាគិ ខេមបូឌា** | **មីកាសា ស្ព័ត** |
| អាសយដ្ឋាន | សហគ្រាសនេះ ស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសខេត្តកោះកុង។ | សហគ្រាសនេះ ស្ថិតនៅផ្លូវជាតិលេខ ៤៨ ស្រុកស្រែអំបិល ខេត្តកោះកុង។ | សហគ្រាសនេះ ស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេស ភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា នៅខេត្តកោះកុង។ | ស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេស ភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា នៅខេត្តកោះកុង។ |
| ចាប់ផ្តើមដំណើរការ និងវិស័យ | សហគ្រាសចាប់បើកនូវឆ្នាំ២០១១ ក្នុងវិស័យកាត់ដេរ។ | សហគ្រាសចាប់បើកនូវឆ្នាំ២០០៧ ក្នុងវិស័យឧស្សាហកម្ម (ផលិតស្ករសរ)។ | គ្រាសនេះចាប់ផ្តើមបើកនៅឆ្នាំ២០១២ ក្នុងវិស័យឧស្សាហកម្ម (គ្រឿងបង្គុំខ្សែភ្លើងរថយន្ត)។ | សហគ្រាសនេះចាប់ផ្តើមបើកនៅឆ្នាំ ២០១៣ ក្នុងវិស័យឧស្សាហកម្ម (ផលិតបាល់)។ |
| ចំនួនបុគ្គលិកសរុប និងចំនួនបុគ្គលិក មានគ្រោះថ្នាក់ក្នុងអំឡុងពេលធ្វើការជាមធ្យមក្នុង១ឆ្នាំ | សហគ្រាសមានបុគ្គលិកចំនួនប្រមាណ ៣៦០ រហូតដល់ ១៦៥០នាក់។ សហគ្រាសនេះមានបុគ្គលិកមានគ្រោះថ្នាក់ក្នុងអំឡុងពេលធ្វើការជាមធ្យមក្នុង១ឆ្នាំ៦៨ នាក់។ | សហគ្រាសមានមានបុគ្គលិកចំនួនប្រមាណ ៣០១រហូតដល់ ៦០០ នាក់។ សហគ្រាសនេះមានបុគ្គលិក មានគ្រោះថ្នាក់ក្នុងអំឡុងពេលធ្វើការជាមធ្យមក្នុង១ឆ្នាំ៥១នាក់ ស្ត្រី ៦នាក់។ | សហគ្រាសមានបុគ្គលិកប្រមាណ ១៥០០ រហូតដល់ ២០០០នាក់។ សហគ្រាសមាន បុគ្គលិកដួលសន្លប់ជា មធ្យមក្នុង១ឆ្នាំ ៨នាក់ (ស្ត្រី៨) របួសជាមធ្យម ក្នុង១ឆ្នាំ ៣៦នាក់ (ស្ត្រី ៣០នាក់) និងផ្សេងៗ ជាមធ្យមក្នុង១ឆ្នាំ ៧២០ នាក់ (ស្ត្រី៥០០នាក់)។ | សហគ្រាសមានបុគ្គលិកប្រមាណ ១០០នាក់និងមានបុគ្គលិកគ្រោះថ្នាក់ក្នុង អំឡុងពេលធ្វើការជាមធ្យម១០ ទៅ ២០នាក់ មានស្ត្រី ចំនួន៩០%។ |
| គិលានដ្ឋានរបស់សហគ្រាស | សហគ្រាសមានរៀបចំគិលានដ្ឋានដែលគោរពទៅតាមប្រកាសលេខ៣៣០ សកបយស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស និងភាពចាំបាច់របស់សហគ្រាស។ តាមរយៈការចុះ | សហគ្រាសមានរៀបចំគិលានដ្ឋានដែលគោរពទៅតាមប្រកាសលេខ៣៣០សកបយ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស។ សហគ្រាសតយល់ឃើញថាការរៀបចំគិលានដ្ឋានក្នុងសហគ្រាស មានសារៈ | សហគ្រាសមានរៀបចំគិលានដ្ឋានដែលគោរពទៅតាមប្រកាសលេខ ៣៣០ សកបយ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស។ | សហគ្រាសមានរៀបចំគិលានដ្ឋានដែលគោរពទៅតាមប្រកាសលេខ ៣៣០ សកបយ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស។ ការរៀបចំគិលានដ្ឋានរបស់គាត់នេះមានគិលានុ |

| | | | | |
|---|---|---|---|---|
| | ពិគ្រោះយោបល់ជាក់ស្តែងគិលានដ្ឋានរបស់សហគ្រាសនេះមានលក្ខណៈល្អប្រសើរ មានគ្រូពេទ្យប្រចាំការ និង វេជ្ជបណ្ឌិតគ្រប់គ្រាន់ក្នុងការផ្លាស់ប្តូរវេនគ្នាប្រចាំការ។ | សំខាន់ ដែលជាសុខមាលភាពមួយចំណែកដែលបានផ្តល់ជូនបុគ្គលិក ក្នុងករណីដែលបុគ្គលិកឈឺអាចជួយសង្គ្រោះបឋមបានដែលជួយកាត់បន្ថយថ្លៃចំណាយរបស់បុគ្គលិកបានខ្លះ។ ក្រោយពីបានទទួលបាននឹងដឹងពីប្រកាសស្តីពីគិលាដ្ឋានសហគ្រាសហើយ ពួកគាត់នឹងរៀបចំទៅតាមអ្វីដែលបាន ចែងនៅក្នុងច្បាប់និងប្រកាស។ | | ឬដ្ឋាយិកាប្រចាំការម្នាក់ និងវេជ្ជបណ្ឌិតម្នាក់ ប្រចាំការ២ម៉ោងក្នុង១ថ្ងៃ ។ |
| **មតិ និងយោបល់ស្តីពីប្រកាស** | សហគ្រាសក៏មានជាមតិផងដែរទៅលើប្រកាសគឺ ប្រកាសនេះមានលក្ខណៈលម្អិត ប៉ុន្តែខាងសហគ្រាសសំណូមពរឱ្យបែងចែកអោយច្បាស់ម្តងទៀតរវាងទំហំគិលានដ្ឋានទៅនឹងគ្រែ និងចំនួននៃបុគ្គលិក និងសុំឱ្យមានសរសេរ ឬពន្យល់ជាអក្សរខ្មែរ ចំពោះពាក្យបច្ចេកទេស និងថ្នាំ។ ទន្ទឹមនោះសហ-គ្រាស នឹងព្យាយាមបំពេញអ្វីដែលខ្វះខាតដើម្បីគោរពទៅតាមច្បាប់ និងប្រកាស។ | តាមរយៈអនុសាសន៍របស់សហគ្រាស ការរៀបចំគិលានដ្ឋាននេះផ្តល់ផលចំនេញដល់និយោជកផងនិងបុគ្គលិកផង។ សហគ្រាស យល់ថាប្រកាសនេះ មានលក្ខណៈសមរម្យហើយ។ | តាមមតិរបស់សហគ្រាសនេះ ចំពោះកំនត់ចំនួនកម្មករនិយោជិត៥០នាក់ឡើងទៅគឺជាការសមស្របមួយ ព្រោះថាចំនួន៥០នាក់នេះ ក៏អាចមានគ្រោះថ្នាក់ឬមានបញ្ហាសុខភាពដែររបស់បុគ្គលិកញឹកញាប់ផងដែរ។ ទន្ទឹមនោះ យោងតាមប្រកាស ចំនួនបុគ្គលិកសុខាភិបាលមានចំនួនសមស្របទៅតាមការផ្តល់សេវាកម្មថែទាំនិងព្យាបាល។ ចំពោះសំភារៈ បរិក្ខារ និងឱសថ នៅក្នុងឧបសម្ព័ន្ធនៃប្រកាសផ្តល់នូវភាពងាយស្រួលពោលគឺមានលក្ខណៈ: អំណោយផលល្អសម្រាប់ការទទួល និង | សហគ្រាសយល់ឃើញថាការរៀបចំគិលានដ្ឋាននេះផ្តល់ផលចំនេញដល់និយោជកផងនិងបុគ្គលិកផង។ |

| | | | | |
|---|---|---|---|---|
| ផ្សេងៗ | គិលាដ្ឋាននូវមាន ទំហំតូចចង្អៀត ប៉ុន្តែមានគ្រូពេទ្យនិងវេជ្ជបណ្ឌិតប្រចាំការប្តូរវេនជារៀងរាល់ថ្ងៃ។ | | សហគ្រាសក៏មានសំណូពពរផងដែរថា ក្រសួងនិងស្ថាប័នពាក់ព័ន្ធត្រូវមានវិធានការយ៉ាងតឹង រឹងនៅក្នុងមាត្រា១នៃច្បាប់ស្តីពីការងារអនុវត្តន៍តាមប្រកាសរួមឱ្យមានប្រសិទ្ធភាពខ្ពស់។ | |

**ថ្ងៃទី២៨ ដល់ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤**

ក្រុមការងារបានចុះទៅកាន់ទីតាំងជាក់ស្តែងក្រុមហ៊ុនទាំងបួន របស់ខេត្តបន្ទាយមានជ័យ និងទទួលបានលទ្ធផលដូចខាងក្រោម

| | ឈ្មោះក្រុមហ៊ុន | | | |
|---|---|---|---|---|
| | TK GarmendSisophon | SP Brother Sisophon | Campack Company Co,.LTD | SC WADO Component (Cambodai) |
| អាសយដ្ឋាន | សហគ្រាសនេះ ស្ថិតនៅភូមិដីឡូតិ៍ សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ។ | សហគ្រាសស្ថិតនៅភូមិដីឡូតិ៍ សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ។ | សហគ្រាសស្ថិតនៅផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ | សហគ្រាសនេះ ស្ថិតនៅផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ |
| ចាប់ផ្តើមដំណើរការ និងវិស័យ | សហគ្រាសចាប់បើកនូវឆ្នាំ២០១៤ ក្នុងវិស័យកាត់ដេរ។ | សហគ្រាសចាប់បើកនូវឆ្នាំ២០១៤ ក្នុងវិស័យកាត់ដេរ។ | | សហគ្រាសចាប់បើកនូវឆ្នាំ២០១២ ក្នុងវិស័យឧស្សាហកម្ម។ |
| ចំនួនបុគ្គលិកសរុប និងចំនួនបុគ្គលិក មានគ្រោះថ្នាក់ក្នុងអំឡុងពេលធ្វើការជាមធ្យមក្នុង១ឆ្នាំ | សហគ្រាសមានបុគ្គលិកចំនួនប្រមាណ ៦០១ រហូតដល់៨០០ ដែលមានបុគ្គលិកដួលសន្លប់ជាមធ្យមក្នុង១ឆ្នាំ៨នាក់ (ស្ត្រី៨នាក់)។ | សហគ្រាសមានបុគ្គលិកចំនួន៣១៩ នាក់ ប្រុសមាន៨០ នាក់ ជនបរទេសមាន ៦នាក់។ សហគ្រាសនេះមាន បុគ្គលិកមានគ្រោះថ្នាក់ក្នុងអំឡុងពេលធ្វើការជា មធ្យមក្នុង១ឆ្នាំ ៨០ នាក់ (ប្រុស៨០នាក់)។ | | មានបុគ្គលិកប្រមាណ ៦០១ រហូតដល់ ៨០០នាក់។ សហគ្រាសនេះមានបុគ្គលិកមានគ្រោះថ្នាក់ក្នុងអំឡុងពេលធ្វើការជាមធ្យមក្នុង១ឆ្នាំ៣ នាក់ (ប្រុស៣នាក់) |
| គិលានដ្ឋានរបស់សហគ្រាស | សហគ្រាសមានរៀប | សហគ្រាសមានរៀប | | សហគ្រាសមាន |

| | | | | |
|---|---|---|---|---|
| | ចំគិលានដ្ឋានដែលគោរពទៅតាមប្រកាសលេខ ៣៣០/សកបយ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស។ | ចំគិលានដ្ឋានដែលគោរពទៅតាមប្រកាសលេខ៣៣០/សកបយ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស។ សហគ្រាសគ យល់ឃើញថាការរៀបចំគិលានដ្ឋានក្នុងសហគ្រាស មានសារៈសំខាន់ ដែលជាសុខមាលភាពមួយចំណែកដែលបានផ្តល់ជូនបុគ្គលិក ក្នុងករណីដែលបុគ្គលិកឈឺអាចជួយសង្គ្រោះបឋមបានដែលជួយកាត់បន្ថយថ្លៃចំណាយរបស់បុគ្គលិកបានខ្លះ។ | | រៀបចំគិលានដ្ឋានដែលគោរពទៅតាមប្រកាសលេខ ៣៣០/សកបយ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស ។ |
| **មតិ និងយោបល់ស្តីពីប្រកាស** | យោងតាមមតិរបស់សហគ្រាសចំពោះឧបករណ៍ប្រើប្រាស់ដែលក្រសួងបានកំណត់មានភាពងាយស្រួលក្នុងការជួយដល់ពលករកុនងរោងចក្រ ប៉ុន្តែសហគ្រាសយល់ឃើញថាចំនួនបុគ្គលិក៥០នាក់ គឺមានចំនួនតិចពេកក្នុងការបើកគិលានដ្ឋាន។ | យោងតាមមតិរបស់សហគ្រាសការរៀបចំគិលានដ្ឋានគួរតែចាប់ពី១០០នាក់ឡើងទៅ និងគួរតែមានអ្នកប្រចាំការតែម្នាក់មិនចាំបាច់ត្រូវមានពេទ្យប្រចាំការ ព្រោះបើគ្រោះថ្នាក់ធ្ងន់ធ្ងរត្រូវបញ្ជូនទៅពេទ្យស្រាប់ហើយ។ | | តាមរយៈអនុសាសន៍របស់សហគ្រាស ការរៀបចំគិលានដ្ឋាននេះផ្តល់ផលចំនេញដល់និយោជក និងបុគ្គលិកផង។ សហគ្រាសយល់ថាប្រកាសនេះមានលក្ខណៈសមរម្យហើយ។ |
| **ផ្សេងៗ** | | | ពុំទាន់មានការរៀបចំគិលានដ្ឋាន។ | |

**សេចក្តីសន្និដ្ឋានរួមលើប្រកាសស្តីពី "ការរៀបចំគិលានដ្ឋានសហគ្រាស"**

បន្ទាប់ពីក្រុមការងារយើងខ្ញុំសហការជាមួយមន្ទីរខេត្ត ព្រះសីហនុ ខេត្តកោះកុង និងខេត្តបន្ទាយមានជ័យ បានចុះពិនិត្យទីតាំងជាក់ស្តែងរួចហើយយើងអាចសន្និដ្ឋានបានថា ការរៀបចំគិលានដ្ឋាននៅក្នុងសហគ្រាសត្រូវបានបង្កើតឡើងទៅតាមច្បាប់ការងារដែលមានចែង និងការចាំបាច់ និងការគិតគូររបស់សហគ្រាសទៅលើបុគ្គលិក។ ចំពោះសហគ្រាសមួយចំនួនតូចនៅពុំទាន់មានគ្រូពេទ្យត្រឹមត្រូវ និងពុំទាន់មានវេជ្ជបណ្ឌិតសម្រាប់សហគ្រាសនៅឡើយទេ។ តាមរយៈអនុសាសន៍របស់សហគ្រាស ការរៀបចំគិលានដ្ឋាននេះផ្តល់ផលចំនេញដល់និយោជកផង និងបុគ្គលិកផង។ និយោជកនឹងមិនខាតកម្លាំងពលកម្មនូវពេលដែលបុគ្គលិក

របស់គាត់មានគ្រោះថ្នាក់ ឬមានជំងឺបន្តិចបន្តួច។ ចំពោះបុគ្គលិកវិញនឹងមានការព្យាបាលបឋមទាន់ពេលវេលា ទន្ទឹមនោះខាងសហគ្រាសក៏មានជាមតិផងដែរទៅលើប្រកាស គឺប្រកាសនេះមានលក្ខណៈលម្អិតពីកាតព្វកិច្ចរបស់ក្រុមហ៊ុនមានរៀបរាប់ផងដែរនូវសម្ភារៈ និងឧបករណ៍សម្រាប់គិលាដ្ឋាន។ ខាងសហគ្រាសនឹងព្យាយាមបំពេញអ្វីដែលខ្វះខាតដើម្បីគោរពទៅតាមច្បាប់ និងប្រកាស។ ជាចុងបញ្ចប់សហគ្រាសសំណូមពរ ឱ្យបែងចែកអោយច្បាស់ម្តងទៀតរវាងទំហំគិលានដ្ឋានទៅនឹងគ្រែនិងចំនួននៃបុគ្គលិក ពោលគឺសូមបញ្ជាក់អោយកាន់តែច្បាស់លើទំហំគិលានដ្ឋាន និងសុំឱ្យមានសរសេរឬពន្យល់ជាអក្សរខ្មែរចំពោះពាក្យបច្ចេកទេស និងថ្នាំ។ ទន្ទឹមនោះមានសហគ្រាសមួយចំនួនតូចគាត់គិតថាចំពោះគ្រូពេទ្យប្រចាំការមានតែមួយនាក់គឺគ្រប់គ្រាន់ហើយ និងមិនចាំបាច់ត្រូវមានវេជ្ជបណ្ឌិតប្រចាំការទេ ព្រោះថានូវដែលមានគ្រោះថ្នាក់ធ្ងន់ធ្ងរត្រូវបញ្ជូនទៅមន្ទីរពេទ្យ។ ព្រមជាមួយគ្នានោះខាងសហគ្រាសក៏មានមតិផងដែរ គឺចំនួនមនុស្ស ៥០នាក់ គឺមានចំនួនតិចពេកក្នុងករណីរៀបចំគិលានដ្ឋាន។

រាជធានីភ្នំពេញ, ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៥
អ្នកធ្វើរបាយការណ៍

**សំ សំណាង**

បានឃើញ និងឯកភាព
អ្នកគ្រប់គ្រងគម្រោង RIA
ហត្ថលេខា

**ម៉ិច សុខា**